# វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន គឺជាសក្ខីភាពនៃកិច្ចសហការស្អិតស្អួត និងវប្បធម៌សន្ទនា ដើម្បីរួមគ្នាដោះស្រាយបញ្ហាប្រឈម និង ក្ដីកង្វល់ របស់ធុរជន និងវិនិយោគិន ក្នុងគោលដៅជំរុញការអភិវឌ្ឍវិស័យឯកជន និងសេដ្ឋកិច្ច នៅកម្ពុជា

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានថ្លែងនូវសារ និងអនុសាសន៍គន្លឹះសំខាន់ៗ ដើម្បីអភិវឌ្ឍវិស័យឯកជននៅកម្ពុជាក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៩ នៅវិមានសន្តិភាព កាលពីព្រឹកថ្ងៃចន្ទ ទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០២៣។

រាជរដ្ឋាភិបាល នឹងប្រកាន់ខ្ជាប់នូវគោលការណ៍ "ហ៊ានស្ដាប់ ហ៊ានថា ហ៊ានទទួលខុសត្រូវ និងហ៊ានវះកាត់" ដោយក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីពេញអង្គលើកដំបូង រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដើម្បី កំណើន, ការងារ, សមធម៌, ប្រសិទ្ធភាព និងចីរភាព ដោយឈរលើបេសកកម្ម ជាប្រវត្តិសាស្ត្រ ចម្បង២៖ ទី១. ថែរក្សា និងបំប៉នសុខសន្តិភាព ដែលសម្រេចបានដោយលំបាក ជាមួយនឹងការលះបង់មិនអាចកាត់ថ្លៃបាន និងពូនជ្រំចលនាការនៃកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍជារួម និង ទី២. កសាង និងពង្រឹងមូលដ្ឋានគ្រឹះ សម្រាប់ជំរុញសម្ទុះនៃការអភិវឌ្ឍប្រទេសជាតិ ដោយឆ្លងកាត់បង្គោលចរនៃការប្រែក្លាយខ្លួនជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០, ឆ្ពោះទៅសម្រេចបាន ចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០ តាមរយៈការកសាងភាពធន់នៃវិស័យទាំង៥ រួមមាន៖ វិស័យសាធារណៈ, វិស័យសេដ្ឋកិច្ច, វិស័យហិរញ្ញវត្ថុ, វិស័យមូលធនមនុស្ស និងសង្គម, និងវិស័យបរិស្ថានព្រមទាំងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

ជាមួយគ្នានេះ អ្វីដែលគោលដៅចម្បង និងបានដាក់ចេញយុទ្ធសាស្ត្រក្នុងការអនុវត្តឱ្យបាន សម្រាប់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា ហើយបានកំណត់នូវយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ គឺមនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា។ បន្ថែមពីនេះគោលនយោបាយអាទិភាពចំនួន ៦ និងវិធានការគន្លឹះទាំង ៥ ត្រូវបានកំណត់ និងចង្អុលបង្ហាញសម្រាប់អនុវត្ត ដើម្បីសម្រេចបានក្ដីសង្ឃឹម និងការ ចង់បានរបស់ប្រជាពលរដ្ឋទូទាំងប្រទេស។ ជាមួយគ្នានេះ សម្ដេចធិបតីបានគូសរំលឹកអំពីកម្មវិធី គោលនយោបាយអាទិភាពចំនួន ៦៖ ទី១. ការពង្រីកសេវាថែទាំសុខភាព, ទី២. ការបណ្ដុះបណ្ដាល ជំនាញវិជ្ជាជីវៈ និងបច្ចេកទេស, ទី៣. ការធ្វើស្ថាបនូបនីយកម្ម កម្មវិធីជាតិជំនួយសង្គម, ទី៤. ការអនុវត្តយុទ្ធសាស្ត្រស្ដីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ, ទី៥. យន្តការសម្រប

សម្រួល និងកម្មវិធី ហិរញ្ញប្បទាន និងទី៦. ការដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្មទៅគ្រប់ ឃុំ សង្កាត់។ ការអនុវត្ត វិធានការគន្លឹះចំនួន ៥ រួមមាន៖ ទី១. ការពង្រឹងសមត្ថភាពរដ្ឋបាលសាធារណៈ, ទី២. ការលើក កម្ពស់គុណភាពអប់រំ, ទី៣. ការលើកកម្ពស់គុណភាពសេវាសុខាភិបាល, ទី៤. ការពង្រឹងការ អនុវត្តគោលនយោបាយ ភូមិឃុំ សង្កាត់ មានសុវត្ថិភាព និងទី៥. ការពង្រឹង និងលើកកម្ពស់ និង ប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌។

សម្រាប់បញ្ហាប្រឈម និងកង្វល់ដែលនៅសេសសល់ ក៏ដូចជាការគិតគូរសម្រួលបន្ថែមសម្រាប់វិស័យមួយចំនួន ដើម្បីកាត់បន្ថយថ្លៃធ្វើធុរកិច្ច, លើកកម្ពស់ភាពប្រកួតប្រជែង និងជំរុញកំណើនសេដ្ឋកិច្ច សម្តេចធិបតីនាយករដ្ឋមន្ត្រីបានដាក់ចេញនូវវិធានការកែទម្រង់គន្លឹះ និងមុតស្រួចដូចតទៅ៖

## ១. ការកែសម្រួលបរិយាកាសធុរកិច្ច និងការវិនិយោគ៖

១.១ ការបំពេញការតព្វកិច្ចគណនេយ្យ និងសវនកម្ម៖ ទី១. ផ្តល់ការអនុគ្រោះដល់សហគ្រាសមិនរងសវនកម្មឯករាជ្យ ដែលមិនបានដាក់បញ្ជូនរបាយការណ៍ ហិរញ្ញវត្ថុមកនិយ័តករគណនេយ្យ និងសវនកម្មរហូតដល់ដំណាច់ខែកុម្ភៈ ឆ្នាំ២០២៤, ទី២. និយ័តករគណនេយ្យ និងសវនកម្មត្រូវផ្តល់ភាពទន់ភ្លន់ក្នុងការអនុវត្តនូវពិន័យអន្តរការណ៍ និងការពិនិត្យដោះស្រាយការតវ៉ានានាពីវិស័យឯកជន, ទី៣. ធ្វើវិសោធនកម្មអនុក្រឹត្យស្តីពីពិន័យអន្តរការណ៍ ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងប្រកាសស្តីពីកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ, ទី៤. ជំរុញការផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ និងការបណ្តុះបណ្តាលបច្ចេកទេសស្តង់ដាគណនេយ្យជូនដល់តំណាង និងគណនេយ្យករ របស់សហគ្រាស សាធារណជន និងមន្ត្រីសាធារណៈពាក់ព័ន្ធ, ទី៥. ជំរុញការរៀបចំសទ្ទានុក្រមវាក្យស័ព្ទគណនេយ្យ និងសវនកម្ម និងការបកប្រែស្តង់ដាគណនេយ្យ និងសវនកម្ម ជាភាសាខ្មែរ និងទី៦. ពិនិត្យលទ្ធភាពក្នុងការរៀបចំស្តង់ដាគណនេយ្យសាមញ្ញ សម្រាប់សហគ្រាសជាអ្នកជាប់ពន្ធមធ្យម និងតូចសម្រាប់រយៈពេលអន្តរកាលមួយ មុននឹងឈានទៅរកការអនុវត្តស្តង់ដាគណនេយ្យអន្តរជាតិ។

១.២ ការលើកម្ពស់តម្លាភាពនៃការស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបផលិតផលក្លែងក្លាយ

១.៣ ការបន្តជំរុញការរៀបចំចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន៖ ទី១ អភិវឌ្ឍមុខងារធ្វើបច្ចុប្បន្នកម្មព័ត៌មានក្រុមហ៊ុន-សហគ្រាសទាំងចាស់ និង ថ្មី លើប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន សម្រេចឱ្យបានពេញលេញមុន ខែ វិច្ឆិកា ឆ្នាំ

២០២៤, ទី២. បញ្ចប់ការបញ្ចូលសេវាសាធារណៈរបស់ក្រសួង-ស្ថាប័ន ដែលបានប្រកាសចូលរួមមកក្នុងប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (CamDX) រួចហើយ នៅក្នុងដំណាក់កាលទី ៣ កាលពីខែ មិថុនា ឆ្នាំ ២០២៣ កន្លងទៅ ដែលរួមមាន ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ , ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ក្រសួងយុត្តិធម៌ និង ធនាគារជាតិនៃកម្ពុជា, ទី៣. បញ្ចូលសេវាសាធារណៈ ឬ ប្រព័ន្ធរបស់ក្រសួង-ស្ថាប័នចំនួន ៣ បន្ថែមទៀត ដែលទើបស្នើដាក់បញ្ចូលមកក្នុងប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ក្រោយការប្រកាសដំណាក់កាលទី ៣, រួមមាន ៖ សេវាផ្តល់ការពិនិត្យព័ត៌មានសុរិយោដីតាមប្រព័ន្ធអេឡិចត្រូនិក របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, សេវាផ្តល់បណ្ណសារព័ត៌មាន (ជារូបវន្តបុគ្គល) របស់ក្រសួងព័ត៌មាន, និង ប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការស៊ីវិល របស់ក្រសួងមុខងារសាធារណៈ, ទី៤.ដាក់បញ្ចូលបន្ថែមទៀតនូវសេវាសាធារណៈគន្លឹះរបស់ក្រសួង-ស្ថាប័ន ពាក់ព័ន្ធនឹងការធ្វើធុរកិច្ច ក៏ដូចជាសេវាសាធារណៈណាដែលប្រជាពលរដ្ឋត្រូវការចាំបាច់បំផុត ឬ ជាញឹកញាប់បំផុត មកក្នុងប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ក្នុងក្របខណ្ឌនៃការផ្លាស់ប្តូរទិន្នន័យរួម របស់ រាជរដ្ឋាភិបាលតាមរយៈថ្នាល CamDX ឱ្យសម្រេចបានមុនដំណាច់ឆ្នាំ ២០២៤ ។

១.៤ ការគាំទ្រដល់សហគ្រាសធុនមីក្រូ, តូច និង មធ្យម៖ រាជរដ្ឋាភិបាល ផ្តល់អាទិភាពខ្ពស់ដល់ការជំរុញការអភិវឌ្ឍសហគ្រាសធុនមីក្រូ, តូច និង មធ្យម ឱ្យក្លាយទៅជាឆ្អឹងខ្នងដ៏រឹងមាំនៃសេដ្ឋកិច្ចជាតិ តាមរយៈការដាក់ចេញនូវវិធានការគាំទ្រ និងលើកទឹកចិត្តជាច្រើន ក្នុងយន្តការផ្សេងៗ ដូចជា ៖ ការបង្កើតធនាគារសហគ្រាសធុនតូច និង មធ្យមកម្ពុជា (SME Bank), សហគ្រិនខ្មែរ, មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី «តេជោ», មូលនិធិអភិវឌ្ឍន៍ជំនាញ ជាដើម ។ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ ដែលបានសហការជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ពិនិត្យឡើងវិញរួចរាល់នូវកម្រងសេវាសាធារណៈទាំងអស់របស់ក្រសួង ដោយបានពន្យារសុពលភាព និង កាត់បន្ថយរយៈពេលផ្តល់ និង ថ្លៃសេវា នៃលិខិតអនុញ្ញាត និង អាជ្ញាបណ្ណផ្សេងៗ ក្នុងគោលដៅបន្តគាំទ្រដល់ការអភិវឌ្ឍសហគ្រាសធុនមីក្រូ, តូច និង មធ្យម ជាពិសេស សហគ្រាសកម្មន្តសាល ។

១.៥ ការលើកកម្ពស់តម្លាភាព និង ប្រសិទ្ធភាពនៃការរៀបចំបទដ្ឋានគតិយុត្ត៖ វិស័យឯកជនបានលើកឡើងអំពីការរៀបចំបទដ្ឋានគតិយុត្តច្រើន ដោយបទដ្ឋានគតិយុត្តខ្លះមានភាពត្រួតស៊ីគ្នា និងមិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយ ។ ការតាក់តែងបទដ្ឋានគតិយុត្តមិនសូវបានពិគ្រោះយោបល់ជាមួយវិស័យឯកជន ហើយការដាក់ឱ្យអនុវត្តតែងធ្វើឡើង

ភ្លាមៗ ដោយមិនមានការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងមិនទុកពេលគ្រប់គ្រាន់ដើម្បីឱ្យវិស័យឯកជន អាចសម្របខ្លួន និងរៀបចំផែនការអាជីវកម្មបានទាន់ពេល។ ក្នុងន័យធានាតម្លាភាព និងប្រសិទ្ធភាពនៃការរៀបចំ និងការអនុវត្តបទដ្ឋានគតិយុត្ត, សម្តេចធិបតីនាយករដ្ឋមន្ត្រី ដាក់ចេញជាគោលការណ៍រួម៖ រាល់ការតាក់តែងបទដ្ឋានគតិយុត្តដែលមានការពាក់ព័ន្ធកិច្ចប្រតិបត្តិការរបស់សហគ្រាសអាជីវកម្មនៃវិស័យឯកជន នៅគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវមានការពិគ្រោះយោបល់ជាមួយវិស័យឯកជនពាក់ព័ន្ធសំខាន់ៗ ហើយការដាក់ឱ្យអនុវត្ត ត្រូវមានការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និង ត្រូវទុកពេលអន្តរកាល ៦ ខែយ៉ាងតិច មុននឹងចាប់ផ្តើមអនុវត្ត ។

១.៦ ការពិនិត្យលិខិតអនុញ្ញាត និង អាជ្ញាបណ្ណឡើងវិញ៖ វិស័យឯកជន បានលើកឡើងថាសហគ្រាសក្នុងវិស័យនីមួយៗ ត្រូវស្នើសុំលិខិតអនុញ្ញាត និង/ឬ អាជ្ញាបណ្ណច្រើនពីក្រសួង-ស្ថាប័នផ្សេងគ្នា ដែលលិខិតអនុញ្ញាត និង/ឬ អាជ្ញាបណ្ណមួយចំនួនហាក់ដូចជាមិនចាំបាច់ ហើយមួយចំនួនទៀត មានលក្ខណៈត្រួតស៊ីគ្នា។ ដើម្បីដោះស្រាយបញ្ហានេះ, សម្តេចធិបតីបានប្រគល់ភារកិច្ចជូន គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីសម្របសម្រួល និង ដឹកនាំគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការពិនិត្យឡើងវិញនូវលិខិតអនុញ្ញាត និង អាជ្ញាបណ្ណទាំងអស់ ក្នុងវិស័យនីមួយៗ ដោយចាប់ផ្តើមពីវិស័យទេសចរណ៍ និងវិស័យសហគ្រាសធុនមីក្រូ តូច និង មធ្យម ដើម្បីលុបចេញ ឬ ផ្តួបចូលគ្នា នូវលិខិតអនុញ្ញាត និង អាជ្ញាបណ្ណ ដែលត្រួតស៊ីគ្នា និង កែសម្រួលនីតិវិធី និង ថ្លៃសេវានៃលិខិតអនុញ្ញាត និង អាជ្ញាបណ្ណនីមួយៗ ឱ្យមានភាពច្បាស់លាស់ ពោលគឺធ្វើយ៉ាងណា ធានាថា គ្មាននីតិវិធីមួយណា ដែលបង្កការលំបាក និង ដែលមិនចាំបាច់ដល់ប្រជាពលរដ្ឋឡើយ។

## ២. ការសម្រាលបន្ទុកលើអនុលោមភាព៖

២.១ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបន្តដឹកនាំពង្រឹងយន្តការអធិការកិច្ចអន្តរក្រសួង តាមការសម្រេចរបស់វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី ១៨ នាខែ មីនា ឆ្នាំ ២០១៩ កន្លងទៅ ។ គ្រប់ក្រសួង-ស្ថាប័ន ដែលស្ថិតក្នុងយន្តការអធិការកិច្ចអន្តរក្រសួង រួមទាំងការធ្វើអធិការកិច្ចហត្ថពលកម្មបរទេស ត្រូវប្រកាន់ខ្ជាប់នូវស្មារតីបុរេសកម្ម ជួយដល់វិស័យឯកជនឱ្យចេះវាយតម្លៃកម្រិតអនុលោមភាពរបស់ខ្លួន មុនពេលចុះធ្វើអធិការកិច្ចរួមគ្នា ដូចដែលក្រសួងការងារ និង បណ្តុះបណ្តាល វិជ្ជាជីវៈ បាន និង កំពុងអនុវត្ត «របបស្វ័យប្រកាសអធិការកិច្ចការងារ» លើប្រព័ន្ធអនឡាញ ដែល

អនុញ្ញាតឱ្យវិស័យឯកជនអាចបំពេញព័ត៌មាន និងដឹងភ្លាមៗ អំពីចំណុចមិនអនុលោមភាពរបស់ខ្លួន និង មានរយៈពេលត្រឹម ៤៥ ថ្ងៃ ដើម្បីពិនិត្យឡើងវិញ និង បំពេញបន្ថែមឯកសារ ឬ កែលម្អចំណុចខ្វះខាតណាមួយ ឱ្យបានត្រឹមត្រូវឡើងវិញ ពោលគឺ អាចកែប្រែចំណុច ដែលមិនអនុលោមភាព ទៅជាអនុលោមភាពវិញ ដោយខ្លួនឯង មុនពេលហួសសុពលភាពក្នុងការកែតម្រូវ។ គ្រប់ក្រសួង-ស្ថាប័នត្រូវធានាថា ១ ឆ្នាំ គឺរួមគ្នាចុះអធិការកិច្ចតែ ១ ដងគត់ លើគោលដៅតែមួយ លើកលែងតែមានបណ្តឹងពីបងប្អូនកម្មករ-និយោជិតផ្ទាល់ ឬ មានឧបទ្ទវហេតុណាមួយកើតឡើង ។ គ្រប់ក្រសួង-ស្ថាប័ន ដែលស្ថិតនៅក្នុងយន្តការអធិការកិច្ចអន្តរក្រសួង ត្រូវមានយន្តការទទួលពាក្យបណ្តឹងពីវិស័យឯកជន ដើម្បីទប់ស្កាត់ការឆ្លៀតចុះអធិការកិច្ចដោយឡែករបស់ក្រុមណាមួយ ។

២.២ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវជំរុញការអភិវឌ្ឍន៍ជំនាញ និង ផលិតភាពរបស់កម្មករ-និយោជិត ដោយផ្តល់លទ្ធភាពដល់វិស័យឯកជន អាចចូលរួមសហការអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និង បច្ចេកទេស ដល់កម្មករ-និយោជិត និង ការអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង ស្របតាមច្បាប់ស្តីពីការងារ ដូចជា បង្កើតឱ្យមានកម្មវិធីបណ្តុះបណ្តាលវេនយប់ ឬ ចុងសប្តាហ៍ និង អាចអនុ-ញ្ញាត ឱ្យក្រុមហ៊ុនប្រើប្រាស់អគាររបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ ដើម្បីប៉ប៉ន សមត្ថភាពជំនាញ, បង្កើនជំនាញ ឬ ផ្លាស់ប្តូរជំនាញ ដល់កម្មករ-និយោជិតរបស់ខ្លួន សំដៅជំរុញកំណើនផលិតភាពការងារ និង គាំទ្រដល់ការធ្វើទំនើបកម្មខ្សែច្រវាក់ផលិតកម្ម ឬ ការផ្តល់សេវាកម្ម របស់រោងចក្រ-សហគ្រាស ។

២.៣ ពង្រឹងយន្តការផ្សះផ្សារ និង ដោះស្រាយវិវាទការងារ នៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលជាយន្តការត្រីភាគី, ពង្រឹងលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល និង សមត្ថភាពមន្ត្រីផ្សះផ្សាវិវាទការងារនៅថ្នាក់ក្រសួង និង មន្ទីរ, ព្រមទាំងបង្កើនការ-អប់រំផ្សព្វផ្សាយអំពីច្បាប់, សិទ្ធិ, កាតព្វកិច្ច និង រូបមន្តគណនាអត្ថប្រយោជន៍នានា ដើម្បីកាត់បន្ថយការយល់ច្រឡំ និង នាំឱ្យមានវិវាទការងារ ។

## ៣. ការសម្រួលដល់ធុរកិច្ច ក្រោមដែនសមត្ថកិច្ចពន្ធដារ៖

៣.១ ការបន្តគោលការណ៍មិនយកពន្ធ៖ កន្លងមក, រាជរដ្ឋាភិបាល ក្នុងអាណត្តិមុនៗ បានសម្រេចលុបចោលជាបន្តបន្ទាប់នូវប្រភេទពន្ធមួយចំនួន ដូចខាងក្រោម៖

- ✓ ពន្ធសត្តឃាត,
- ✓ ពន្ធលើរបបម៉ៅការ,

- ✓ ពន្ធតែមប្រិ៍សារពើពន្ធ លើលិខិតរដ្ឋបាល, លិខិតតុលាការ និង ឯកសារអេត្រានុកូលដ្ឋាន,
- ✓ ពន្ធលើមធ្យោបាយដឹកជញ្ជូន៖ ទោចក្រយានយន្ត, ត្រីចក្រយានយន្ត, ត្រាក់ទ័រ និង គ្រឿងយន្តប្រហាក់ប្រហែល និង ជលយានយន្តមានកម្លាំងដល់ ១៥០ សេះ, និង
- ✓ ពន្ធប្រថាប់ត្រាលើលិខិតបង្កើតក្រុមហ៊ុន ។

បន្ថែមលើនេះ, កន្លងមក ក៏មានការលើកលែងពន្ធមួយចំនួនទៀត ដែលរាជរដ្ឋាភិបាល ក្នុងអាណត្តិនេះ នឹងបន្តអនុវត្តជាគោលការណ៍ គឺការមិនយកពន្ធលើ ៖

- ✓ ដីកសិកម្ម, ដីស្រែ ជាលក្ខណៈគ្រួសារ,
- ✓ ពន្ធនាំចូលសម្ភារៈកសិកម្ម,
- ✓ កសិផលកសិកម្ម,
- ✓ ពន្ធអចលនទ្រព្យតម្លៃទាបជាង ១០០ ០០០ ០០០ (មួយរយលាន) រៀល,
- ✓ ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិលើអចលនទ្រព្យពីឪពុកម្ដាយ មកកូន, យាយតា មកចៅ, ប្រពន្ធ និង ប្ដី សម្រាប់អំណោយ តែ ១ លើក និង មរតក,
- ✓ អាករលើតម្លៃបន្ថែម លើមុខទំនិញដែលជាអាហារជាមូលដ្ឋានសម្រាប់ការរស់នៅ ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ រហូតដល់ចុងឆ្នាំ ២០២៨, និង
- ✓ ពន្ធលើប្រាក់បៀវត្សអប្បបរមា របស់មន្ត្រីរាជការគ្រប់ប្រភេទ និង ប្រាក់ឈ្នួលអប្បបរមា របស់កម្មករ-និយោជិត ។

៣.២ ការលុបការបង់ភាស៊ី និង ការបង់ថ្លៃផ្សេងៗទៀត៖ រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា ក៏នឹងបន្តអនុវត្តនូវការលុបការបង់ភាស៊ី និង ការបង់ថ្លៃផ្សេងៗទៀត ចំពោះការលក់ដូររបស់ប្រជាពលរដ្ឋ តាមកញ្ច្រែង, កញ្ជើ, ល្អី នៅតាមទីផ្សារនានា នៅទូទាំងប្រទេស, ព្រមជាមួយនឹងគោលនយោបាយនៃការអនុញ្ញាតឱ្យអាជីវករលក់ដូរតាមផ្សាររដ្ឋ និងទីតាំងផ្សាររដ្ឋមានសិទ្ធិកាន់កាប់ប្រើប្រាស់ និង អាស្រ័យផលលើតូប, រាន, ស្តង់លក់ដូរ និង មានសិទ្ធិផ្ទេរសិទ្ធិទាំងនេះ ឱ្យកូនចៅ ឬ អ្នកដទៃបាន ។

៣.៣ ការអនុគ្រោះពន្ធបន្ថែម៖ ដើម្បីសម្រាលបន្ទុករបស់ប្រជាជនទូទៅ និង វិស័យឯកជន ក្នុងន័យជំរុញសកម្មភាពសេដ្ឋ-កិច្ចនៅក្នុងគ្រប់វិស័យឱ្យមានភាពរស់រវើក, រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា សម្រេចផ្តល់ការអនុគ្រោះបន្ថែមលើប្រភេទពន្ធមួយចំនួន ដូចខាងក្រោម ៖

ទី១ បន្តការលើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់លំនៅឋានគ្រប់ប្រភេទ ដែលមានលក្ខណៈជាបុរី ដែលមានថ្លៃក្រោម ឬ ស្មើ ៧ ម៉ឺនដុល្លារអាម៉េរិក រហូតដល់ដំណាច់ឆ្នាំ ២០២៤,

ទី២ លើកលែងពន្ធប្រថាប់ត្រាបន្ថែមទៀតលើការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់លំនៅឋានគ្រប់ប្រភេទ ដែលមានលក្ខណៈជាបុរី និង មានថ្លៃលើស ៧ ម៉ឺនដុល្លារអាមេរិក ដោយអនុញ្ញាតឱ្យដកទំហំទឹកប្រាក់ ៧ ម៉ឺនដុល្លារអាមេរិក ចេញពីមូលដ្ឋានគិតពន្ធប្រថាប់ត្រា សម្រាប់ការទិញលំនៅឋានក្នុងគម្រោងអភិវឌ្ឍន៍លំនៅឋានជាបុរី ដែលមានអាជ្ញាបណ្ណអាជីវកម្មអចលនវត្ថុ និង បានចុះបញ្ជីត្រឹមត្រូវ រហូតដល់ដំណាច់ឆ្នាំ ២០២៤;

ទី៣ បន្តពន្យារពេលការអនុវត្តពន្ធលើចំណេញមូលធន ទាំង ៦ ប្រភេទ រួមមាន ពន្ធលើចំណេញអចលនទ្រព្យ, ភតិសន្យា, ទ្រព្យវិនិយោគ, កេរ្តិ៍ឈ្មោះអាជីវកម្ម, កម្មសិទ្ធិបញ្ញា និង រូបិយវត្ថុបរទេស រហូតដល់ដំណាច់ឆ្នាំ ២០២៤;

ទី៤ លើកលែងទណ្ឌកម្មរដ្ឋបាល លើពន្ធលើអចលនទ្រព្យ និង/ឬ ពន្ធលើដីធ្លីមិនប្រើប្រាស់ ដោយម្ចាស់អចលនទ្រព្យ អាចបង់តែប្រាក់ពន្ធ ដោយមិនចាំបាច់បង់ពន្ធបន្ថែម និង ការប្រាក់ រហូតដល់ដំណាច់ខែ មិថុនា ឆ្នាំ ២០២៤ ។ ការលើកលែងនេះពុំមានអនុភាពប្រតិសកម្មចំពោះប្រាក់ពន្ធ រួមទាំងទណ្ឌកម្មរដ្ឋបាល (ពន្ធបន្ថែម និង ការប្រាក់) ដែលបានបង់រួចហើយនោះទេ;

ទី៥ លើកលែងការកំណត់ពន្ធឡើងវិញ ដែលរួមមាន៖ ប្រាក់ពន្ធ រួមទាំងទណ្ឌកម្មរដ្ឋបាល (ពន្ធបន្ថែម និង ការប្រាក់) ចាប់ពីឆ្នាំដាក់ឱ្យអនុវត្តពន្ធរហូតដល់ឆ្នាំ ២០២៣ ចំពោះអចលនទ្រព្យ ដែលបានចុះបញ្ជី និង ប្រកាសបង់ពន្ធលើអចលនទ្រព្យ កន្លងមក ខុសតម្លៃដី ឬ សំណង់, ទំហំដី ឬ សំណង់, ប្រភេទសំណង់ ឬ/និង អាយុកាលសំណង់ ។ ចាប់ពីឆ្នាំ ២០២៤ តទៅ, ត្រូវអនុវត្តតាមច្បាប់ និង លិខិតបទដ្ឋានគតិយុត្តជាធរមាន; និង

ទី៦ អនុញ្ញាតឱ្យចុះបញ្ជី និង បង់ប្រាក់ពន្ធ ចាប់ពីឆ្នាំកាន់កាប់ ឬ ទទួលប្រយោជន៍ចុងក្រោយ ចំពោះអចលនទ្រព្យ (មានបណ្ណកម្មសិទ្ធិ ឬ គ្មានបណ្ណកម្មសិទ្ធិ) ដែលពុំធ្លាប់បានចុះបញ្ជី និង ប្រកាសបង់ពន្ធអចលនទ្រព្យកន្លងមក ។

៣.៤ ពន្ធលើដីធ្លីមិនបានប្រើប្រាស់៖ ពាក់ព័ន្ធនឹងពន្ធលើអចលនទ្រព្យ និង ពន្ធលើដីធ្លីមិនបានប្រើប្រាស់នេះ, កន្លងមក មានការភាន់ច្រឡំច្រើនថា ពន្ធទាំងពីរនេះ ហាក់មានភាពត្រួតស៊ីគ្នា។ ដើម្បីឱ្យសាធារណជនយល់កាន់តែច្បាស់, «**ពន្ធលើអចលនទ្រព្យ**», រហូតមកដល់បច្ចុប្បន្ននេះ, រាជរដ្ឋាភិបាល សម្រេចឱ្យអនុវត្តចំពោះតែអចលនទ្រព្យ ដែលស្ថិតនៅក្នុងភូមិសាស្ត្រខណ្ឌទាំង ១៤ នៃរាជធានីភ្នំពេញ និង ក្រុងចំនួន ២៧ នៃខេត្តទូទាំងប្រទេសតែប៉ុណ្ណោះ។ ដោយឡែក, «**ពន្ធលើដីធ្លីមិនបានប្រើប្រាស់**» ត្រូវអនុវត្តលើដីមានសំណង់ និងដីគ្មានសំណង់ ដែលមិនបានប្រើប្រាស់ និង អនុវត្តលើដីធ្លីមិនបានប្រើ

ប្រាស់ ដែលជាទូទៅ គឺជាដីមិនស្ថិតនៅក្នុងរាជធានីភ្នំពេញ និង ក្រុង ។ ការកំណត់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ គឺក្នុងគោលបំណង ៤ រួមមាន៖ (១). ជាឧបករណ៍ទប់ស្កាត់ការទិញដីធំៗរាប់ហិកតា ទុកចោលមិនប្រើប្រាស់ សម្រាប់លក់ដំឡើងថ្លៃ ដើម្បីកេងចំណេញ ឬ ជាសកម្មភាពបរិកប្បកម្ម (Speculation) ដែលធ្វើឱ្យបាត់បង់ផលិតភាពនៃការប្រើប្រាស់ដី ដែលជាធនធាន និង ជាកត្តាផលិតកម្មកម្រមួយរបស់ជាតិ, (២). ជំរុញការប្រើប្រាស់ដីធ្លីឱ្យបានសមស្រប និង មានការអភិវឌ្ឍ, (៣). បង្កើនសកម្មភាពសេដ្ឋកិច្ច និង កម្លាំងការងារ, និង (៤). ធានាការប្រមូលចំណូលជាគុណប្រយោជន៍ដល់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

ដើម្បីបញ្ចៀសការយកពន្ធត្រួតគ្នា និង មិនឱ្យប៉ះពាល់ដល់ប្រជាជនទូទៅ ស្របតាមគោលបំណងនេះ, សម្តេចធិបតីបានដាក់ចេញនូវគោលការណ៍ ឱ្យអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើការកែសម្រួលលិខិតបទដ្ឋានគតិយុត្ត ដើម្បីបន្ធូរបន្ថយលក្ខខណ្ឌ សម្រាប់ទទួលបាន ការលើកលែងពន្ធលើ **ដីធ្លីមិនបានប្រើប្រាស់** ឱ្យមានភាពច្បាស់លាស់ ដូចតទៅ៖

ទី១. ដីដែលជាកម្មវត្ថុនៃពន្ធលើដីធ្លីមិនបានប្រើប្រាស់ សំដៅដល់ដី ដែលនៅក្រៅតំបន់ជាប់ពន្ធលើអចលនទ្រព្យ;

ទី២. ដីដែលជាកម្មវត្ថុនៃពន្ធលើដីធ្លីមិនបានប្រើប្រាស់ ត្រូវបានអនុញ្ញាតឱ្យកាត់ចេញ ៥ ហិកតា ក្នុងមួយកន្លែង;

ទី៣. ចំពោះដីដែលលើសពី ៥ ហិកតា គឺអាចរួចពន្ធលើដីធ្លីមិនបានប្រើប្រាស់ ស្របតាមលក្ខខណ្ឌណាមួយ ដូចខាងក្រោម៖

- ✓ ដីកសិកម្មកំពុងបង្កបង្កើនផល ដោយមានការបញ្ជាក់ពីគណៈកម្មការ ឬ អនុគណៈ-កម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់,
- ✓ ដីកំពុងបម្រើសកម្មភាពសេដ្ឋកិច្ចរបស់រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលបានចុះបញ្ជីពន្ធដារនៅរដ្ឋបាលសារពើពន្ធ,
- ✓ ដីមានសំណង់ ឬ គ្មានសំណង់ស្ថិតក្រោមកិច្ចសន្យាជួល,
- ✓ ដីដែលជាកម្មសិទ្ធិរបស់រាជរដ្ឋាភិបាល ឬ ស្ថាប័នរាជរដ្ឋាភិបាល,
- ✓ ដីសម្បទានសេដ្ឋកិច្ចដែលជួលពីរដ្ឋ, ដីធ្លីរបស់សហគមន៍,
- ✓ ដីជាកម្មសិទ្ធិរបស់រដ្ឋ ដែលបានជួលទៅឱ្យនីតិបុគ្គល ឬ រូបវន្តបុគ្គលណាមួយសម្រាប់ប្រើប្រាស់ជាសកម្មភាពសេដ្ឋកិច្ចផ្សេងៗតាមកិច្ចសន្យា ឬ កិច្ចព្រមព្រៀងរវាងភាគីទាំងពីរ,

- ✓ ដីដែលស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ដែលបម្រើផ្ទាល់ដល់សកម្មភាពកសិកម្ម, ឧស្សាហកម្ម និង សេវាកម្ម, និង
- ✓ ស្របតាមការស្នើសុំដោយក្រុមការងារផ្នែកអប់រំ គឺដីដែលត្រូវបានចុះបញ្ជីជាទ្រព្យសម្បត្តិរបស់សហគ្រាស ក្នុងវិស័យអប់រំ, សិក្សាធិការ និង បណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់គោលដៅបម្រើការងារក្នុងវិស័យដូចបានរៀបរាប់ខាងដើម។ ក្នុងករណីដែលដីនេះ ត្រូវបានលក់ ឬ មិនបានបម្រើតាមគោលដៅខាងលើ, ត្រូវបំពេញកាតព្វកិច្ចពន្ធដារតាមច្បាប់ជាធរមាន ។

ទី៤ ពន្ធលើដីធ្លីមិនប្រើប្រាស់ ស្របតាមគោលការណ៍ខាងលើនេះ ត្រូវចាប់ផ្តើមអនុវត្តចាប់ពីដើមឆ្នាំ ២០២៥ ។

៣.៥ ការសម្រួល និង ពង្រីកវិសាលភាពនៃការអនុគ្រោះពន្ធ ក្នុងវិស័យកសិកម្ម៖ កសិកម្ម គឺជាវិស័យអាទិភាព ដែលរាជរដ្ឋាភិបាល បាននិងកំពុងផ្តល់ការអនុគ្រោះពន្ធ និង ការលើកទឹកចិត្តជាច្រើន ក្នុងគោលដៅគាំទ្រ និង ជំរុញការអភិវឌ្ឍ ឱ្យក្លាយទៅជាចន្ទល់សេដ្ឋកិច្ចមួយដ៏រឹងមាំ ។ ជាក់ស្តែង, ក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី ១៨ កន្លងទៅ, **សម្តេចតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់ការលើកទឹកចិត្តផ្នែកពន្ធដារ ចំពោះសហគ្រាសផលិត, ផ្គត់ផ្គង់ក្នុងស្រុក ឬ នាំចេញផលិតផលកសិកម្ម ចំនួន ៨ មុខ រួមមាន ៖ ស្រូវ, អង្ករ, ពោត, សណ្តែក, ម្រេច, ដំឡូងមី, គ្រាប់ស្វាយចន្ទី និង ជ័រកៅស៊ូ ។ ជារួម, ផលិតផលកសិកម្ម ចំនួន ៨ មុខនេះទទួលបានការលើកលែងពន្ធកាត់ទុកលើការទូទាត់ចំពោះការផ្គត់ផ្គង់សេវា ដោយបុគ្គលមិនស្ថិតក្នុងរបបស្វ័យប្រកាស, អាករលើតម្លៃបន្ថែមលើការផ្គត់ផ្គង់សេវាឱ្យដល់សហគ្រាសទទួលការផ្គត់ផ្គង់ ជាបន្ទុករដ្ឋ, និង ពន្ធអប្បបរមា ក្នុងករណីបានកាន់នូវបញ្ជីគណនេយ្យត្រឹមត្រូវ ស្របតាមច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត ជាធរមាន ។

សម្រាប់ការរៀបចំវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី ១៩ នេះ, ជាពិសេសតាមរយៈក្រុមការងារផ្នែកសិកម្ម និង កសិ-ឧស្សាហកម្ម (ក្រុម “ក”) និង ក្រុមការងារផ្នែកស្រូវ-អង្ករ (ក្រុម “ឈ”), វិស័យឯកជន មកពីអនុវិស័យជាច្រើននៃវិស័យកសិកម្ម បានស្នើសុំប្រហាក់ប្រហែលគ្នា ពោលគឺ ៖ (១). ស្នើសុំពន្យារសុពលភាពនៃការអនុគ្រោះពន្ធដែលនឹងផុតកំណត់នៅដំណាច់ឆ្នាំ ២០២៣ នេះ, (២). ស្នើសុំផ្តល់ការអនុគ្រោះដូចគ្នាដល់ផលិតផលកសិកម្មមួយចំនួនទៀត, និង (៣). ស្នើសុំបន្ថែមការលើកលែងប្រាក់រំដោះពន្ធលើប្រាក់ចំណូល ។ ជាការឆ្លើយតប, រាជរដ្ឋាភិបាលសម្រេចផ្តល់ជូនតាមការស្នើសុំរបស់វិស័យឯកជន ដោយដាក់ចេញជាគោលការណ៍ ដូចខាងក្រោម ៖

ទី១. បន្តការលើកទឹកចិត្តផ្នែកពន្ធដារចំនួន ២ ឆ្នាំ បន្ថែមទៀត ស្របតាម «ប្រកាសលេខ ២៥២ សហវ.ប្រក ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៩ ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារចំពោះសហគ្រាសផលិត, ផ្គត់ផ្គង់ក្នុងស្រុក ឬ នាំចេញ ស្រូវ, អង្ករ, ពោត, សណ្តែក, ម្រេច, ដំឡូងមី, គ្រាប់ស្វាយចន្ទី, និងជ័រកៅស៊ូ» ។ ការបន្តការលើកទឹកចិត្តនឹងត្រូវបានពិនិត្យជាក់ស្តែង អំពីភាពចាំបាច់នៃការបន្ត ឬ មិនបន្ត នៅក្នុងរយៈពេល ២ ឆ្នាំម្តង;

ទី២. បន្ថែមផលិតផលកសិកម្មចំនួន ៥ មុខ ដែលកំពុងមានសក្តានុពល គឺ ៖ «មៀនប៉ៃលិន», «ស្វាយ», «វារីវប្បកម្ម», «ការចិញ្ចឹមសត្វ» និង «ផលិតផលដូងប្រេងនៅក្នុងស្រុក ដែលជាវត្ថុធាតុដើមផលិតចំណីសត្វ» ដោយអនុវត្តយន្តការលើកទឹកចិត្តដូចគ្នានឹង «ប្រកាសលេខ ២៥២ សហវ.ប្រក ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៩ ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារចំពោះសហគ្រាសផលិត, ផ្គត់ផ្គង់ក្នុងស្រុក ឬនាំចេញ ស្រូវ, អង្ករ, ពោត, សណ្តែក, ម្រេច, ដំឡូងមី, គ្រាប់ស្វាយចន្ទី, និងជ័រកៅស៊ូ» ដោយភ្ជាប់លក្ខខណ្ឌតម្រូវឱ្យមានការផ្តល់បញ្ជីឈ្មោះអ្នកផ្គត់ផ្គង់ទំនិញ ឬ សេវាកម្ម ឱ្យបានច្បាស់លាស់ទៅអគ្គនាយកដ្ឋានពន្ធដារ សម្រាប់ផ្ទៀងផ្ទាត់

ទី៣. បន្តលើកលែងប្រាក់រំដោះពន្ធលើប្រាក់ចំណូល ចំពោះសហគ្រាសដាំដុះ, ផលិត និង ផ្គត់ផ្គង់ក្នុងស្រុក ឬនាំចេញផលិតផលកសិកម្ម រួមមាន ស្រូវ, អង្ករ, ពោត, សណ្តែក, ម្រេច, ដំឡូងមី, គ្រាប់ស្វាយចន្ទី, និង ជ័រកៅស៊ូ, ដោយបន្ថែម មៀនប៉ៃលិន, ស្វាយ, វារីវប្បកម្ម, ការចិញ្ចឹមសត្វ និង ផលិតផលដូងប្រេងនៅក្នុងស្រុក ដែលជាវត្ថុធាតុដើមផលិតចំណីសត្វ ក្នុងស្រុក សម្រាប់រយៈពេល ២ ឆ្នាំ គឺ ពីឆ្នាំ ២០២៤ ដល់ឆ្នាំ ២០២៥ ។

៣.៦ ការផ្តល់ការលើកទឹកចិត្តផ្សេងទៀត៖ ក្រៅពីវិស័យកសិកម្ម និង ទេសចរណ៍, រាជរដ្ឋាភិបាល ក៏បានទទួលការស្នើសុំពាក់ព័ន្ធនឹងវិស័យផ្សេងទៀត ពីក្រុមការងារផ្នែកនីតិកម្មពន្ធដារ និងអភិបាលកិច្ច (ក្រុម “ឃ”) និង ក្រុមការងារផ្នែកផលិតកម្មកែច្នៃសម្រាប់នាំចេញ និង កិច្ចសម្រួលពាណិជ្ជកម្ម (ក្រុម “ធ”) ផងដែរ, ជាពិសេសពាក់ព័ន្ធនឹងសហគ្រាស ជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ **(គ.ល.គ.-QIP)** ។ ឆ្លើយតបទៅនឹងការស្នើសុំនេះ, រាជរដ្ឋាភិបាល សម្រេចដាក់ចេញនូវវិធានការ ដូចខាងក្រោម៖

ទី១. ផ្តល់ការលើកលែងពន្ធអប្បបរមា ដល់សហគ្រាសជា គ.ល.គ. សម្រាប់ឆ្នាំដំបូង ដែលមិនទាន់មានរបាយការណ៍សវនកម្មឯករាជ្យ ដោយកំណត់លក្ខខណ្ឌតម្រូវឱ្យសហគ្រាសផ្តល់របាយការណ៍សវនកម្មឯករាជ្យមកអគ្គនាយកដ្ឋានពន្ធដារ យ៉ាងយូរត្រឹមដំណាច់ខែ មិថុនា នៃឆ្នាំបន្ទាប់;

ទី២. ផ្តល់ការអនុគ្រោះព្យួរទុកជាបណ្តោះអាសន្ន នូវការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលប្រចាំខែរហូតដល់ដំណាច់ឆ្នាំ ២០២៥ សម្រាប់សហគ្រាស ជា គ.ល.គ. រួមមានសហគ្រាសផលិតស្លាកយីហោសម្រាប់សម្លៀកបំពាក់ (Garment Logo), ផលិតផលស្រោមដៃ (Glove), ស្រោមជើង (Sock), កន្សែង (Towel), ស្រោមខ្នើយ (Pillow Case), ស្រោមភួយ (Duvet Cover), កម្រាលពូក (Bed Sheet), និង កម្រាលតុ (Table Clothes) ដូចសហគ្រាសក្នុងវិស័យវាយនភណ្ឌដែរ ។ ដើម្បីទទួលបានការលើកទឹកចិត្តនេះ, សហគ្រាសត្រូវផ្សារភ្ជាប់ជាមួយនឹងអនុលោមភាពសារពើពន្ធ ស្របតាមច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត ដូចមានចែងក្នុងប្រការ ៤ នៃប្រកាសលេខ ០០២ សហវ.ប្រក.អពដ ចុះថ្ងៃទី ៦ ខែ មករា ឆ្នាំ ២០២៣ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ;

ទី៣. កែសម្រួលប្រកាសលេខ ២១៧ សហវ.ប្រក ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០២២ ស្តីពីការលើកទឹកចិត្តចំពោះការកែតម្រូវលិខិតប្រកាសពន្ធដោយស្ម័គ្រចិត្ត ដើម្បីការលើកលែងទណ្ឌកម្មរដ្ឋបាល ចំពោះការកែតម្រូវលិខិតប្រកាស ដោយស្ម័គ្រចិត្ត ដោយទុកពេលរហូតដល់ដំណាច់ខែ មិថុនា ឆ្នាំ ២០២៤ ។ ដោយឡែក, ការស្នើសុំកែតម្រូវលិខិតប្រកាសក្រោយកាលបរិច្ឆេទនេះ នឹងត្រូវទទួលរងទណ្ឌកម្ម ស្របតាមច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត ជាធរមាន ។ ទន្ទឹមនឹងនេះ, ការអនុញ្ញាតនេះ នឹងមិនត្រូវបានអនុវត្តចំពោះ ការកែតម្រូវលើលទ្ធផល ដែលត្រូវបានរកឃើញ ក្នុងអំឡុងពេលសវនកម្មពន្ធដារឡើយ; និង

ទី៤. រាជរដ្ឋាភិបាលបានផ្តល់នូវការលើកទឹកចិត្តមួយចំនួន សម្រាប់អាជីវកម្មនៅក្នុងវិស័យទេសចរណ៍, ជាពិសេស អាជីវកម្មទេសចរណ៍នៅក្នុងខេត្តសៀមរាប ។

៣.៧ **ការកែទម្រង់រដ្ឋបាលសារពើពន្ធ៖** ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ, រដ្ឋបាលសារពើពន្ធនៅកម្ពុជា បានធ្វើការកែទម្រង់យ៉ាងលឿនគួរឱ្យកត់សម្គាល់ ដើម្បីសម្រួលដល់ការបំពេញកាតព្វកិច្ចសារពើពន្ធរបស់វិស័យឯកជន ។ ទោះជាយ៉ាងនេះក្តី, យើងទាំងអស់គ្នាត្រូវទទួលស្គាល់ថា ការកែទម្រង់រដ្ឋបាលសារពើពន្ធ គឺជាកិច្ចការ ដែលមានភាពស្មុគស្មាញខ្ពស់ផ្នែកបច្ចេកទេស និង ត្រូវការពេល ដើម្បីរៀបចំជាជំហានៗ ។ នៅក្នុងកិច្ចដំណើរការនៃការរៀបចំវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី ១៩ នេះ, រាជរដ្ឋាភិបាល ទទួលបានការស្នើសុំច្រើន តាមរយៈយន្តការក្រុមការងារផ្នែកនីតិកម្មពន្ធដារ និង អភិបាលកិច្ច (ក្រុម “ឃ”) ក៏ដូចជាយន្តការក្រៅផ្លូវការ ជុំវិញការធ្វើសវនកម្មត្រួតស៊ីគ្នា និង ភាពមិនប្រកដប្រជា ក្នុងការវាយតម្លៃពន្ធឡើងវិញ (Tax Reassessment) ជាដើម

។ ដើម្បីដោះស្រាយបញ្ហាទាំងអស់នេះបាន ប្រកបដោយប្រសិទ្ធភាព និង តម្លាភាព សម្រាប់រយៈពេលវែងទៅមុខ, រាជរដ្ឋាភិបាល សម្រេចដាក់ចេញនូវវិធានការ ដូចខាងក្រោម ៖

ទី១. បង្កើតស្តង់ដាររួមឱ្យច្បាស់លាស់ ប្រកបដោយតម្លាភាព សម្រាប់ការអនុវត្តរវាងមន្ត្រីពន្ធដារ និងមន្ត្រីពន្ធដារ និង មន្ត្រីពន្ធដារ និង អ្នកជាប់ពន្ធ តាមរយៈការរៀបចំសៀវភៅណែនាំស្តីពីស្តង់ដានីតិវិធីប្រតិបត្តិ (SOP) ពាក់ព័ន្ធនឹង ៖

- ✓ សវនកម្មពន្ធដារ និង បែបបទ និង នីតិវិធីនៃការធ្វើសវនកម្មពន្ធដារ សម្រាប់មន្ត្រីពន្ធដារ និង អ្នកជាប់ពន្ធ,
- ✓ ការអង្កេតសហគ្រាស និង បែបបទ និង នីតិវិធីនៃការធ្វើអង្កេតសហគ្រាស,
- ✓ ការអង្កេតអចលនទ្រព្យ និង បែបបទ និង នីតិវិធីនៃការធ្វើអង្កេតអចលនទ្រព្យ,
- ✓ ពន្ធលើដីធ្លីមិនប្រើប្រាស់ និង បែបបទ និង នីតិវិធី សម្រាប់មន្ត្រីពន្ធដារ និង អ្នក-ជាប់ពន្ធ,
- ✓ ពន្ធលើអចលនទ្រព្យ និង បែបបទ និង នីតិវិធី សម្រាប់មន្ត្រីពន្ធដារ និង អ្នកជាប់-ពន្ធ,
- ✓ ពន្ធប្រថាប់ត្រា និង បែបបទ និង នីតិវិធី សម្រាប់មន្ត្រីពន្ធដារ និង អ្នកជាប់ពន្ធ,
- ✓ ពន្ធលើមធ្យោបាយដឹកជញ្ជូន និង បែបបទ និង នីតិវិធី សម្រាប់មន្ត្រីពន្ធដារ និង អ្នកជាប់ពន្ធ,
- ✓ ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ និង បែបបទ និងនីតិវិធី សម្រាប់មន្ត្រីពន្ធដារ និង អ្នកជាប់ពន្ធ, និង
- ✓ ពន្ធតាមរបបស្វ័យប្រកាស និង បែបបទ និងនីតិវិធី សម្រាប់មន្ត្រីពន្ធដារ និង អ្នកជាប់ពន្ធ ។

ទី២. ផ្តល់អាទិភាពដល់ការរៀបចំ SOP ពាក់ព័ន្ធនឹងការធ្វើសវនកម្ម ឱ្យបានឆាប់បំផុត ដោយត្រូវមានការបញ្ជាក់ឱ្យបានច្បាស់ ពី ៖

- ✓ ប្រភេទ, បែបបទ និង នីតិវិធី នៃការធ្វើសវនកម្មពន្ធដារ និង ការស៊ើបអង្កេតបទ-ល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ,
- ✓ មុខងារ និង ភារកិច្ចរបស់អង្គភាពពាក់ព័ន្ធ,
- ✓ សិទ្ធិ និង កាតព្វកិច្ចរបស់អ្នកជាប់ពន្ធ និង រដ្ឋបាលសារពើពន្ធ,
- ✓ ក្រមសីលធម៌វិន័យ និង វិជ្ជាជីវៈរបស់មន្ត្រីសវនករពន្ធដារ និង មន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដោយត្រូវមានការធ្វើបច្ចុប្បន្នភាព និង

ពង្រឹងការអនុវត្តការងាររបស់ គណៈកម្មការគ្រប់គ្រងការអនុវត្តការងារសវនកម្មពន្ធដារ និង ស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ,

- ✓ យន្តការទទួលពាក្យបណ្ដឹង, និង
- ✓ យន្តការតាមដាន, ត្រួតពិនិត្យ និង វាយតម្លៃការអនុវត្ត ។

ទី៣. ក្នុងករណីមិនឯកភាពទៅនឹងការអនុវត្តរបស់មន្ត្រីពន្ធដារ ដែលមិនស្របតាម SOP ដែលបាន និងកំពុងរៀបចំ, អ្នកជាប់ពន្ធ អាចធ្វើការតវ៉ាទៅអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ គណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ ដើម្បីដោះស្រាយ, និង

ទី៤. សម្រាប់សហគ្រាស ដែលបានចុះបញ្ជីត្រឹមត្រូវ, ការអនុវត្តកាលបរិច្ឆេទនៃការជូនដំណឹងជាផ្លូវការផ្សេងៗ (សម្រាប់គោលដៅដាក់ពិន័យលើសកម្មភាពយឺតយ៉ាវណាមួយ) ត្រូវគិតចាប់ពីកាលបរិច្ឆេទបានទទួលលិខិត ជាជាងកាលបរិច្ឆេទនៃការចេញលិខិត ។

## ៤. កិច្ចសម្រួលពាណិជ្ជកម្ម ក្រោមដែនសមត្ថកិច្ចគយ៖

ដើម្បីបន្តសម្រួលដល់ការធ្វើពាណិជ្ជកម្ម និង លើកកម្ពស់ភាពប្រកួតប្រជែងរបស់កម្ពុជា ទាំងក្នុងក្របខណ្ឌតំបន់ និង សកលលោក នាពេលបច្ចុប្បន្ន, រាជរដ្ឋាភិបាល សម្រេចដាក់ចេញនូវវិធានការ ដូចខាងក្រោម ៖

ទី១. លើកលែងការបង់កម្រៃបែបបទគយ (Customs Processing Fee) ចំពោះទំនិញនាំចេញ-នាំចូល ដែលមានតម្លៃក្រោម ១ ០០០ ដុល្លារអាម៉េរិក; និង កាត់បន្ថយកម្រៃប្រតិវេទន៍គយពី ១៥ ០០០ រៀល មក ៨ ០០០ រៀល ក្នុងមួយប្រតិវេទន៍ចំពោះទំនិញនាំចេញ-នាំចូល ដែលមានតម្លៃក្រោម ១ ០០០ ដុល្លារអាម៉េរិក ។

ទី២. លើកលែងការបង់កម្រៃស្កេន ចំពោះកុងតឺន័រ ដែលមិនបានឆ្លងកាត់ម៉ាស៊ីនស្កេន ។

ទី៣. អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា បន្តធ្វើការងារជាមួយវិស័យឯកជន ក្នុងការកាត់បន្ថយថ្លៃសេវាឡជីស្ទីក តាមរយៈការពិនិត្យឡើងវិញនូវថ្លៃសេវានានា, និង ការកាត់បន្ថយ ឬ ការធ្វើសាមញ្ញបនីយកម្មនីតិវិធីគយ ព្រមទាំងការជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ។

ទី៤. ដាក់ឱ្យអនុវត្ត ចាប់ពីថ្ងៃទី ១ ខែ មករា ឆ្នាំ ២០២៤ នេះតទៅ នូវវិធាន និង នីតិវិធីសម្រាប់ការរាយការណ៍អំពីទំនិញ (Cargo Declaration) និង ការបំពេញបែបបទគយមុនពេលទំនិញមកដល់ (Pre-Arrival Processing) តាមប្រព័ន្ធអេឡិច-

ត្រូនិក ស្របតាម «ប្រកាសលេខ ៧៨៨ សហវ.ប្រក.អគរ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០២៣ ស្ដីពីនីតិវិធីបំពេញបែបបទគយមុនពេលទំនិញមកដល់» ។ នីតិវិធីនេះនឹងអនុញ្ញាតឱ្យធុរជនអាចបញ្ជូនព័ត៌មាន តាមប្រព័ន្ធអេឡិចត្រូនិក មុនពេលទំនិញមកដល់ការិយាល័យគយ ដើម្បីអាចយកទំនិញចេញបានលឿន ពេលទំនិញមកដល់ ដោយមិនចាំបាច់រង់ចាំយូរ ។

ទី៥. បែងចែកប្រភេទទំនិញ ដើម្បីពន្លឿនបែបបទគយ តាមរយៈការដាក់ឱ្យអនុវត្ត ចាប់ពីថ្ងៃទី ១ ខែ មករា ឆ្នាំ ២០២៤ នេះតទៅ នូវវិធាន និង នីតិវិធី សម្រាប់ការបំពេញបែបបទគយ ចំពោះបញ្ញើប្រៃសណីយ៍, បញ្ញើរហ័ស និង ទំនិញពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិកឆ្លងកាត់ព្រំដែន ។

ទី៦. ដាក់ឱ្យអនុវត្ត ចាប់ពីថ្ងៃទី ១ ខែ មករា ឆ្នាំ ២០២៤ នេះតទៅ នូវ៖

- ✓ ការធ្វើស្វ័យប្រវត្តិកម្មពេញលេញលើនីតិវិធីផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ និង សំអាងដើមកំណើតទំនិញ ក្នុងប្រព័ន្ធប្រតិវេទន៍តម្លៃគិតពន្ធគយ (CVDS),
- ✓ ការតភ្ជាប់ប្រព័ន្ធ ដើម្បីបញ្ជូនដោយស្វ័យប្រវត្តិនូវទិន្នន័យប្រតិវេទន៍តម្លៃគិតពន្ធគយ, ការបញ្ជាក់តម្លៃគិតពន្ធគយ និង ការផ្ដល់អត្រាពន្ធអនុគ្រោះ ពីប្រព័ន្ធ CVDS ទៅប្រព័ន្ធ ASYCUDA, និង
- ✓ ការបោះពុម្ពលិខិតបញ្ជាក់ការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ និង លិខិតបញ្ជាក់ការផ្ទៀងផ្ទាត់សំអាងដើមកំណើតទំនិញទម្រង់ក្រដាស អាចធ្វើឡើងក្នុងករណីមានការស្នើសុំរបស់ម្ចាស់ទំនិញ ឬ តំណាង ។

ទី៧. ឆ្លើយតបទៅនឹងការលើកឡើងអំពីថ្លៃចំណាយខ្ពស់, ការប្រើប្រាស់ឯកសារក្នុងទម្រង់រឹង (Hard Copy) ច្រើន និង ការជួបគ្នាផ្ទាល់ជាមួយមន្ត្រីច្រើនកន្លែង, អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា ត្រូវរៀបចំដាក់អនុវត្តនូវផែនការសកម្មភាពជាក់លាក់សំដៅ ៖

- ✓ កាត់បន្ថយថ្លៃចំណាយ លើការបំពេញបែបបទបញ្ចេញទំនិញពីគយ និង កែសម្រួលថ្លៃសេវាឱ្យបានសមរម្យឡើងវិញ;
- ✓ រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីអនុញ្ញាតឱ្យប្រើប្រាស់ឯកសារភ្ជាប់ ក្នុងទម្រង់អេឡិចត្រូនិក ជាឯកសារផ្លូវការ;
- ✓ កែសម្រួលនីតិវិធីប្រតិវេទន៍គយ ក្នុងប្រព័ន្ធ ASYCUDA និង ប្រព័ន្ធ E-Customs ដោយជំរុញការប្រើប្រាស់ឯកសារទម្រង់អេឡិចត្រូនិក និង កាត់បន្ថយឯកសារ ជាក្រដាស; និង

- ✓ ពង្រឹងយន្តការច្រកចេញ-ចូលតែមួយនៅការិយាល័យគយ ដោយកាត់បន្ថយ នីតិវិធី និង ការជួបគ្នាផ្ទាល់ជាមួយមន្ត្រី ។

ទី៨. ជំរុញ និង បញ្ចប់ការរៀបចំដំណាក់កាលទី ៣ នៃប្រព័ន្ធបញ្ជរតែមួយជាតិ (National Single Window) ដើម្បីបញ្ចូលអាជ្ញាបណ្ណ, លិខិតអនុញ្ញាត, វិញ្ញាបនបត្រ និង ឯកសារផ្សេងៗ (LPCOs) របស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ សំដៅជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឱ្យបានជាអតិបរមា ក្នុងការស្នើសុំឯកសារនាំចេញ-នាំចូល ។

ទី៩. សម្រួលឱ្យបានជាអតិបរិមា នូវការត្រួតពិនិត្យទំនិញសម្រាប់ការនាំចេញ តាមរយៈការត្រួតពិនិត្យ ដែលផ្អែកលើហានិភ័យ រួមទាំងការប្រើប្រាស់ម៉ាស៊ីនស្កេន ដោយកាត់បន្ថយការត្រួតពិនិត្យឱ្យនៅក្រោម ១០% ព្រមទាំងលើកលែងការបង់កម្រៃស្កេនចំពោះកុងតឺន័រ ដែលមិនបានឆ្លងកាត់ម៉ាស៊ីនស្កេន ។

ទី១០. អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា បន្តជំរុញការបណ្តុះបណ្តាល និង ការផ្តល់អាជ្ញាបណ្ណជើងសារគយ ។

ទី១១. អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា ត្រូវអនុញ្ញាតឱ្យមានការផ្តល់សេវាធ្វើការបន្ថែមម៉ោងរបស់មន្ត្រីគយនៅពេលយប់ នៅតាមផៃស្ងួត ដោយរៀបចំការកំណត់ប្រាក់ម៉ោងឱ្យបានសមរម្យ ដើម្បីពន្លឿនការនាំចេញ ។

ទី១២. បន្តជំរុញការអនុវត្តកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត (Authorized Economic Operator - AEO) និង កែលម្អប្រព្រឹត្តកម្មលើកទឹកចិត្ត សម្រាប់ធុរជនល្អបំផុត (Best Traders) ។

ទី១៣. វិស័យឯកជន ស្នើសុំឱ្យមានការពង្រឹងការគ្រប់គ្រងលើការនាំចូលសាច់ជ្រូកបង្កក, មាន់, ស៊ុត និង ត្រី ខុសច្បាប់ ដែលមានថ្លៃថោក និង គុណភាពទាប ដែលធ្វើឱ្យអ្នកចិញ្ចឹមក្នុងស្រុកមិនអាចប្រកួតប្រជែងបាន ដោយស្មើភាព ព្រមទាំងប៉ះពាល់ដល់សុខភាពរបស់ប្រជាជនកម្ពុជាទូទាំងប្រទេស ។ ក្នុងន័យនេះ, ដើម្បីលើកកម្ពស់ការប្រកួតប្រជែងស្មើភាព និង ការពារសុខភាពរបស់ប្រជាជន, រាជរដ្ឋាភិបាល សម្រេចដាក់ចេញនូវវិធានការ ដូចខាងក្រោម៖

- ✓ ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវពង្រឹងឱ្យបានម៉ត់ចត់បំផុតនូវការហាមនាំចូលម្ហូប ឬចំណីអាហារណាដែលខូចគុណភាព ឬគុណភាពទាប ដែលប៉ះពាល់ដល់សុខភាព មិនថាឡើយតែសាច់ជ្រូកបង្កក, មាន់, ស៊ុត និង ត្រី ខុសច្បាប់ មកកាន់ព្រះរាជាណាចក្រកម្ពុជា,

- ✓ កំណត់ច្រកទ្វារព្រំដែន ដែលអនុញ្ញាតឱ្យមានការនាំចូលសាច់ជ្រូកបង្កក, មាន់, ស៊ុត និង ត្រី ដើម្បីបង្កភាពងាយស្រួល ក្នុងការគ្រប់គ្រង និង ត្រួតពិនិត្យការនាំចូលខុសច្បាប់ ក្នុងរូបភាពផ្សេងៗ,
- ✓ ធ្វើវិសោធនកម្ម អនុក្រឹត្យលេខ ១៧ អនក្រ.បក ស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និង ទំនិញជាប់កម្រិតកំណត់ ដើម្បីតម្រូវឱ្យមានការស្នើសុំលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ចំពោះការនាំចូល សាច់ជ្រូកបង្កក, មាន់, ស៊ុត និង ត្រី សំដៅធានាការពិនិត្យគុណភាព និង ការពារសុខភាពរបស់ប្រជាជន ស្របតាមការកំណត់នៃលិខិតបទដ្ឋានគតិយុត្ត ជាធរមាន, និង
- ✓ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវប្រើប្រាស់ប្រព័ន្ធបញ្ជរតែមួយជាតិ (National Single Window) សម្រាប់សម្រួលដល់ការស្នើសុំលិខិតអនុញ្ញាត ឱ្យបានលឿន ។

ទី១៤. ធ្វើវិសោធនកម្ម អនុក្រឹត្យលេខ ១២ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០២០ ស្តីពីការកែសម្រួលអត្រាអាករនាំចេញលើមុខទំនិញកៅស៊ូ ដោយសហការជាមួយវិស័យឯកជន ដើម្បីកំណត់ថ្លៃមធ្យមភាគ និង រូបមន្តមូលដ្ឋានគិតពន្ធជ័រកៅស៊ូនាំចេញ របស់កម្ពុជា ដើម្បីឱ្យកាន់តែមានភាពប្រាកដនិយម ។

## ៥. ការលើកកម្ពស់ការដឹកជញ្ជូន និង ហេដ្ឋារចនាសម្ព័ន្ធ៖

ការបញ្ជូនទំនិញពីកន្លែងផលិតទៅកាន់ទីផ្សារ ក្នុងស្រុក និង អន្តរជាតិ ពឹងផ្អែកលើគុណភាពនៃសេវាឡូជីស្ទីក និង ដឹកជញ្ជូន ។ វិស័យឯកជនតែងលើកឡើងថា កង្វះសេវាឡូជីស្ទីក និង ថ្លៃដឹកជញ្ជូនខ្ពស់ ប៉ះពាល់ដល់ភាពប្រកួតប្រជែងរបស់កម្ពុជា ។ ក្នុងន័យនេះ, រាជរដ្ឋាភិបាល បានបង្កើនការវិនិយោគលើវិស័យនេះ ជាបន្តបន្ទាប់, ជាពិសេស ការវិនិយោគលើការកសាងហេដ្ឋារចនាសម្ព័ន្ធ ។ សម្រាប់វិស័យនេះ, បញ្ហាមួយ ដែលមានការស្នើសុំកន្លងមក គឺការដំឡើងកម្រិតទម្ងន់ដឹកជញ្ជូនសរុបពី ៤០ តោនទៅដល់ ៤៥ តោន ដើម្បីកាត់បន្ថយ ថ្លៃដឹកជញ្ជូន, ជាពិសេស ក្នុងវិស័យ កសិកម្ម ។ ពាក់ព័ន្ធបញ្ហានេះ, សម្រេចធិបតីបាន ផ្តល់ការអនុញ្ញាតជាគោលការណ៍លើការដំឡើងកម្រិត ទម្ងន់រថយន្តដឹកទំនិញពី ៤០ តោនទៅដល់ ៤៥ តោន ។ ដើម្បីអនុវត្តការងារនេះ ឱ្យបានឆាប់, ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវធ្វើវិសោធនកម្មច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងសិក្សាពីបច្ចេកទេស ឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បី

កំណត់ប្រភេទរថយន្ត និង ប្រភេទផ្លូវ ដែលអាចប្រើប្រាស់បាន សម្រាប់ការដំឡើងកម្រិតទម្ងន់នេះ ។

ទី១. ការស្នើសុំបញ្ចុះពន្ធ និងអាករលើរថយន្តដឹកជញ្ជូន, រាជរដ្ឋាភិបាលមិនទាន់អាចមានលទ្ធភាពបញ្ចុះបន្ថែមនាពេលនេះទេ ដោយសារចំណូលពីពន្ធ និង អាករលើរថយន្ត គឺជាប្រភពចំណូលមួយដ៏សំខាន់របស់រាជរដ្ឋាភិបាល។ រាជរដ្ឋាភិបាលបានបញ្ចុះអាករពិសេសម្តងរួចទៅហើយ តាមរយៈអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី ៩ ខែកុម្ភៈ ឆ្នាំ ២០២១, ក្នុងនោះ៖ (១). ពីអត្រា ៤០% មក ២៥% លើមុខទំនិញរថសណ្តោង និង រ៉ឺម៉ក គ្រប់ប្រភេទ (រថយន្តដឹកកុងតែន័រ); (២). ពីអត្រា ៤០% មក ៣០% លើមុខទំនិញរថយន្តដឹកទំនិញដែលមានទម្ងន់សរុប (GVW) លើសពី ៥ តោន; និង (៣). ពីអត្រា ៤០% មក ៣០% លើមុខទំនិញរថយន្តបែន, រថយន្តស្ទូច និង រថយន្ត ឯកទេសផ្សេងទៀត ។ ទន្ទឹមនេះដែរ, អត្រាពន្ធនាំចូលលើរថយន្តដឹកជញ្ជូនជាទូទៅ គឺ ១៥% ប៉ុណ្ណោះ; ប៉ុន្តែ, អត្រានេះ មានកម្រិត 0% ប្រសិនបើរថយន្តដឹកជញ្ជូន ត្រូវបាននាំចូលពីប្រទេសដៃគូ ដែលមានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយកម្ពុជា ។

ទី២. ការស្នើសុំឱ្យគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ផ្តល់ឥណទានដែលមានអត្រាការប្រាក់ទាប, រាជរដ្ឋាភិបាលក៏មិនអាចមានលទ្ធភាពផ្តល់ជូនបានដែរ ដោយសារអត្រាការប្រាក់ គឺអាស្រ័យដោយគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ជាអ្នកកំណត់។

## ៦. ការស្តារ និង ការលើកស្ទួយការអភិវឌ្ឍវិស័យទេសចរណ៍៖

ទេសចរណ៍ គឺជាវិស័យដ៏សំខាន់មួយ ដែលបានផ្តល់នូវការងារជាច្រើនដល់ប្រជាពលរដ្ឋយើង និង បានចូលរួមចំណែកយ៉ាងច្រើននៅក្នុងសេដ្ឋកិច្ចជាតិ។ ដូចដែលយើងទាំងអស់គ្នាបានដឹងហើយថា វិស័យទេសចរណ៍បានទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីវិបត្តិជំងឺកូវីដ-១៩ នាពេលកន្លងមក ។ រហូតដល់ពេលនេះ, យើងឃើញថា តួលេខទេសចរ ដែលបានមកដល់ប្រទេសកម្ពុជា មានការកើនឡើង, ទាំងតួលេខពីក្រសួងទេសចរណ៍ និង គ្រឹះស្ថានអង្គរ ។ ជាការពិត, វិស័យទេសចរណ៍មានកំណើន តែមិនទាន់ដល់កម្រិតមុនពេលវិបត្តិជំងឺកូវីដ-១៩, ហើយការកើនឡើងនេះទៀតសោត ក៏មានស្ថានភាពមិនដូចគ្នា នៅតាមគោលដៅទេសចរណ៍សំខាន់, ជាពិសេសនៅខេត្តសៀមរាប ដែលជាខេត្តទេសចរណ៍ដ៏ធំមួយរបស់កម្ពុជា ។

សម្តេចធិបតីនាយករដ្ឋមន្ត្រី ប្រកាសជូនជនរួមជាតិថា រាជរដ្ឋាភិបាលផ្តួចផ្តើមដាក់ចេញនូវកម្មវិធីពិសេសមួយ គឺ៖ «**ទស្សនាសៀមរាប ឆ្នាំ ២០២៤**» ដែលនៅក្នុងកម្មវិធីនេះ រាជរដ្ឋាភិបាលនឹងដាក់ចេញនូវវិធានការមួយចំនួន សំដៅជំរុញឱ្យវិស័យទេសចរណ៍នៅក្នុងខេត្តសៀមរាប មានសម្ទុះងើបឡើងវិញ ដូចខាងក្រោម ៖

ទី១. ក្រសួងទេសចរណ៍ត្រូវរៀបចំឡើងវិញ និង ដាក់ឱ្យដំណើរការ ក្រុមប្រឹក្សាទេសចរណ៍ ដោយមានការចូលរួមពីស្ថាប័នរដ្ឋ និង វិស័យឯកជនពាក់ព័ន្ធ ឱ្យបានឆាប់បំផុត ។ ការដាក់ចេញនូវក្រុមប្រឹក្សាទេសចរណ៍ នឹងអាចដោះស្រាយបាននូវបញ្ហាប្រឈមដែលវិស័យឯកជនជួបប្រទះជាប្រចាំថ្ងៃ, ការរៀបចំ និង ដាក់ចេញផែនការ ឬយុទ្ធសាស្ត្រអភិវឌ្ឍវិស័យទេសចរណ៍ និង ការចូលរួមដោះស្រាយនូវបញ្ហាប្រឈមរយៈពេលមធ្យម ។ល។;

ទី២. ចំពោះមុខ, របស់ក្រុមប្រឹក្សាទេសចរណ៍នេះ ក្រោមការដឹកនាំរបស់ក្រសួងទេសចរណ៍ ត្រូវទទួលភារកិច្ចរៀបចំ និង ដាក់ចេញ នូវផែនការសកម្មភាពជាក់លាក់ដើម្បីអនុវត្តកម្មវិធីពិសេស «**ទស្សនាសៀមរាប ឆ្នាំ ២០២៤**» ឱ្យបានរួចរាល់នៅមុនដំណាច់ឆ្នាំ ២០២៣ ។ អ្វីដែលខ្ញុំចង់ឃើញសម្រាប់ផែនការសកម្មភាពនេះ គឺជាការគិតគូរដោះស្រាយបញ្ហាប្រឈមជាខ្សែច្រវាក់តម្លៃទាំងមូល សម្រាប់វិស័យទេសចរណ៍ នៃខេត្តសៀមរាប ដែលមានជាអាទិ៍៖ ការផ្សព្វផ្សាយ, ការតភ្ជាប់ជើងហោះហើររវាងតំបន់ទេសចរណ៍សំខាន់ៗ, ការកែសម្រួល និង ការផ្តល់សេវានៅពេលមកដល់, ពេលស្នាក់នៅ និង ពេលត្រឡប់ទៅវិញ, តម្រូវការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធជារួម ក៏ដូចជាការកែលម្អបន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធ និង សោភ័ណភាព ពីព្រលានយន្តហោះថ្មី មកកាន់ក្រុងសៀមរាប, ថ្លៃសំបុត្រចូលទស្សនារមណីយដ្ឋាននានា និង ថ្លៃប្រតិបត្តិការក្នុងវិស័យអាកាសចរណ៍ ។ល។ និយាយជារួម, ផែនការនេះត្រូវតែមានភាពទាក់ទាញ និង ជាកាតាលីករជំរុញវិស័យទេសចរណ៍ក្នុងខេត្តសៀមរាប ឱ្យមានសម្ទុះឡើងវិញ នៅឆ្នាំ ២០២៤ នេះ ។ ផែនការសកម្មភាពនេះ ក៏ត្រូវមានការបែងចែកការទទួលខុសត្រូវច្បាស់លាស់រវាងវិស័យរដ្ឋ និង វិស័យឯកជន, គិតគូរពីតម្រូវការថវិកា និង ការតាមដាន និង វាយតម្លៃ ។ល។ ក្នុងស្មារតី «រួមគិត, រួមធ្វើ និង រួមទទួលខុសត្រូវ» ។

ទី៣. បញ្ហាបដិសណ្ឋារកិច្ចតាមច្រកទ្វារព្រំដែន៖ ចំណាប់អារម្មណ៍ដំបូងបំផុតរបស់ភ្ញៀវទេសចរបរទេស គឺនៅពេលដែលពួកគេជួប និង ទទួលសេវាពីមន្ត្រីប៉ូលីសអន្តោ

ប្រវេសន៍ ។ ដើម្បីលើកកម្ពស់ការផ្តល់សេវាល្អ ដល់ទេសចរ, អគ្គនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ នឹងដាក់ចេញបន្ថែមនូវវិធានការចំនួន ៣ រួមមាន៖

- ✓ ការរៀបចំសម្របសម្រួលកែលម្អការបំពេញបែបបទពេលមកដល់ (e-arrival card) ពី ៣ ទម្រង់ (អន្តោប្រវេសន៍, គយ, ចត្តាឡីស័ក) មកនៅតែ ១ ទម្រង់ពេលគឺ ក្នុងទម្រង់អេឡិចត្រូនិក ដែលនឹងត្រូវចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ ២០២៤ តទៅ;
- ✓ រៀបចំជាប្រព័ន្ធ Hotline ដើម្បីទទួលពាក្យបណ្តឹងផ្សេងៗភ្លាមៗ ទាក់ទងនឹងការផ្តល់សេវារបស់មន្ត្រីអន្តោប្រវេសន៍នៅតាមគោលដៅសំខាន់ៗ និង
- ✓ បង្កើតប្រព័ន្ធតាមដានត្រួតពិនិត្យ ដោយបំពាក់ប្រព័ន្ធស្វ័យប្រវត្តិកម្ម និង ប្រព័ន្ធកាមេរ៉ានៅតាមគោលដៅសំខាន់ៗដើម្បីត្រួតពិនិត្យការងារប្រចាំថ្ងៃរបស់មន្ត្រីប៉ូលីសអន្តោប្រវេសន៍។

ទី៤. ការពង្រីកវិសាលភាពបណ្ណព្រំដែន៖ វិស័យឯកជនបានលើកសំណូមពរឱ្យពង្រីកវិសាលភាពនៃបណ្ណព្រំដែន ដើម្បីអនុញ្ញាតឱ្យភ្ញៀវ មានលទ្ធភាពធ្វើដំណើរកំសាន្តឆ្លងពីព្រំប្រទល់ មកដល់ខេត្តសៀមរាបតែម្តង ។ ពាក់ព័ន្ធនឹងសំណើពង្រីកវិសាលភាពបណ្ណព្រំដែន, រាជរដ្ឋាភិបាលទទួលយកនូវសំណើនេះ ដើម្បីដោះស្រាយ ។

ទី៥. ការផ្តល់ហិរញ្ញប្បទានដល់ប្រតិបត្តិករទេសចរណ៍នៅក្នុងខេត្តសៀមរាប៖ ដោយមើលឃើញនូវការលំបាករបស់ប្រតិបត្តិករទេសចរណ៍ក្នុងខេត្តសៀមរាប ក្នុងការទទួលបាននូវហិរញ្ញប្បទាន ដើម្បីយកទៅប្រើប្រាស់ ក្នុងការស្តារ, បើកឡើងវិញ ឬ កែលម្អអាជីវកម្ម, រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវវិធានការចំនួន ២ ដូចខាងក្រោម៖

- ✓ អនុញ្ញាតឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុរៀបចំឥណទានឡើងវិញ ចំពោះវិស័យទេសចរណ៍នៅខេត្តសៀមរាប ជូនអតិថិជនដែលជួបប្រទះការលំបាកផ្នែកហិរញ្ញវត្ថុបណ្តោះអាសន្ន ដោយមិនចាំបាច់ធ្វើសំវិធានធន រយៈពេល ១២ ខែ ។
- ✓ ធនាគារសហគ្រាសធុនតូច និង មធ្យមកម្ពុជា នឹងរៀបចំជាកម្មវិធីផ្តល់កម្ចីដោយផ្ទាល់ ជាមួយនឹងទឹកប្រាក់បឋមចំនួន ៥០ លានដុល្លារអាមេរិក ដល់ប្រតិបត្តិករទេសចរណ៍នៅខេត្តសៀមរាប ជាមួយនឹងអត្រាការប្រាក់សមរម្យ និង លក្ខខណ្ឌអនុគ្រោះផ្សេងទៀត ដើម្បីអនុញ្ញាតឱ្យបងប្អូនយើង ដែលជាប្រតិបត្តិករទេសចរណ៍អាចទទួលបាននូវហិរញ្ញប្បទាន ក្នុងចំនួនទឹកប្រាក់សមស្របតាមប្រភេទអាជីវកម្ម។

ទី៦. ការលើកទឹកចិត្តផ្នែកពន្ធដារ៖ ដើម្បីជួយរក្សាលំនឹង និង សម្រួលបន្ទុកហិរញ្ញវត្ថុសម្រាប់អាជីវកម្មទេសចរណ៍ រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវវិធានការ ដូចខាងក្រោម៖

- ✓ លើកលែងការបង់ពន្ធប្រចាំខែគ្រប់ប្រភេទ លើកលែងតែអាករលើតម្លៃបន្ថែម និង អាករលើការស្នាក់នៅ ចំពោះ សណ្ឋាគារ, ផ្ទះសំណាក់, ក្រុមហ៊ុនភ្នាក់ងារទេសចរណ៍ និង ភោជនីយដ្ឋាន ដែលបានចុះបញ្ជីជាមួយអគ្គនាយកដ្ឋានពន្ធដារ និង មានសកម្មភាពអាជីវកម្ម នៅខេត្តសៀមរាប ពីខែ តុលា ឆ្នាំ ២០២៣ រហូតដល់ចប់ឆមាសទី ១ ឆ្នាំ ២០២៤ ។ អាជីវកម្មទាំងនេះ នៅតែមានកាតព្វកិច្ចដាក់លិខិតប្រកាសពន្ធអាករ និង ប្រើប្រាស់ប្រព័ន្ធអនឡាញ សម្រាប់ការគ្រប់គ្រងអាករលើតម្លៃបន្ថែម (E-VAT) ជារៀងរាល់ខែ ក្នុងអំឡុងពេលនេះ, និង
- ✓ លើកលែងពន្ធលើប្រាក់ចំណូលសម្រាប់ឆ្នាំ ២០២៣ ចំពោះសណ្ឋាគារ, ផ្ទះសំណាក់, ភោជនីយដ្ឋាន និង ក្រុមហ៊ុនភ្នាក់ងារទេសចរណ៍ ដែលបានចុះបញ្ជីជាមួយអគ្គនាយកដ្ឋានពន្ធដារ និង មានសកម្មភាពអាជីវកម្ម នៅខេត្តសៀមរាប ។ អាជីវកម្មទាំងនេះនៅតែមានកាតព្វកិច្ច ដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ២០២៣ យ៉ាងយឺតបំផុតឱ្យបានមុនដំណាច់ខែ មីនា ឆ្នាំ ២០២៤ ។ ចំពោះប្រាក់រំដោះពន្ធលើប្រាក់ចំណូលដែលបានបង់រួច នឹងត្រូវអនុញ្ញាតជាឥណទានសម្រាប់កាត់កងជាមួយពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ២០២៤ ។
- ✓ លើកលែងបំណុលពន្ធទាំងអស់ ដែលមានការិយបរិច្ឆេទ មុនឆ្នាំ ២០២៣ ដែលក្នុងនោះរួមមាន ប្រាក់ពន្ធ, ពន្ធបន្ថែម, ការប្រាក់, ពន្ធបន្ថែម ២៥% និង ការប្រាក់រត់បន្តចំពោះសហគ្រាសដែលស្ថិតក្នុងវិស័យទេសចរណ៍ រួមមាន សណ្ឋាគារ, ផ្ទះសំណាក់, ភោជនីយដ្ឋាន និង ក្រុមហ៊ុនទីភ្នាក់ងារទេសចរណ៍ ដែលបានចុះបញ្ជីពន្ធដារ និង មានសកម្មភាពអាជីវកម្មស្ថិតក្នុងខេត្តសៀមរាប,
- ✓ មិនចុះធ្វើសវនកម្ម លើអាជីវកម្មក្នុងវិស័យទេសចរណ៍ រួមមាន សណ្ឋាគារ, ផ្ទះសំណាក់, ភោជនីយដ្ឋាន និង ក្រុមហ៊ុនទីភ្នាក់ងារទេសចរណ៍ នៅក្នុងការិយបរិច្ឆេទឆ្នាំ ២០២០ ដល់ ២០២២ សម្រាប់រាជធានីភ្នំពេញ, ខេត្តព្រះសីហនុ, ខេត្តកែប និង ខេត្តកំពត, និង
- ✓ មិនចុះធ្វើសវនកម្ម លើអាជីវកម្ម ក្នុងវិស័យទេសចរណ៍ រួមមាន សណ្ឋាគារ, ផ្ទះសំណាក់, ភោជនីយដ្ឋាន និង ក្រុមហ៊ុនទីភ្នាក់ងារទេសចរណ៍ នៅខេត្តសៀមរាប ក្នុងការិយបរិច្ឆេទ ឆ្នាំ ២០២០ ដល់ ២០២៣ ។

ទី៧. លើកលែងការពិន័យអន្តរការណ៍ជាប្រាក់ ចំពោះការហួសសុពលភាពអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ និង អ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍

ទី៨. ការតភ្ជាប់ជើងហោះហើរដោយត្រង់ពីគោលដៅទេសចរណ៍ល្បីមកសៀមរាប៖ ក្រសួងទេសចរណ៍ត្រូវធ្វើការពិភាក្សានៅក្រោមយន្តការក្រុមប្រឹក្សាទេសចរណ៍ និង ដាក់ចេញជាវិធានការ ដើម្បីជំរុញការតភ្ជាប់ ដោយការហោះហើរដោយត្រង់ រវាងគោលដៅទេសចរណ៍ល្បីៗ នៅក្នុងបណ្តាប្រទេសជិតខាងមកខេត្តសៀមរាប ដូចជាការហោះហើរដោយត្រង់រវាង ***ភូកេត-សៀមរាប, បាលី-សៀមរាប, ដាណាំង-សៀមរាប ឬ សេប៊ូ-សៀមរាប*** ។ បន្ថែមពីលើការរៀបចំផែនការសកម្មភាព និង វិធានការនានា សម្រាប់អនុវត្តកម្មវិធីពិសេស **«ទស្សនាសៀមរាប ឆ្នាំ ២០២៤»** ក៏នៅមានសំណូមពរផ្សេងទៀត ដែលខ្ញុំសូមជម្រាបជូនអង្គពិធីទាំងមូល ដូចខាងក្រោម៖

- ✓ ទី១. បញ្ហាទិដ្ឋាការ៖ វិស័យឯកជនបានស្នើឱ្យពិនិត្យពិចារណាលើប្រព័ន្ធទិដ្ឋាការដែលមានភាពបត់បែន និង ទាក់ទាញសម្រាប់ទីផ្សារអាទិភាព ។ សំណូមពរនេះ មិនមែនជាដំណោះស្រាយដែលឆ្លើយតបចំបញ្ហានោះទេ ព្រោះថា កម្ពុជា បាន និង កំពុងផ្តល់នូវកិច្ចសម្រួលច្រើនរួចទៅហើយ តាមរយៈការផ្តល់ទិដ្ឋាការពេលមកដល់ និង ការផ្តល់ទិដ្ឋាការអេឡិចត្រូនិក ហើយបញ្ហាថ្លៃមិនមែនជារបាំងរាំងភ្ញៀវទេសចរមកកម្ពុជា នោះឡើយ ។
- ✓ ទី២. បញ្ហាកិត្តិនាមមិនល្អរបស់កម្ពុជា៖ យើងទាំងអស់គ្នាយល់ដូចគ្នាថា ការកែលម្អកិត្តិនាមរបស់ប្រទេសកម្ពុជាជាកិច្ចការងារចាំបាច់ និង ជាកត្តាដ៏សំខាន់មួយ ក្នុងការទាក់ទាញទេសចរណ៍ និងវិនិយោគិនមកកម្ពុជា។ ដូច្នេះ, ការខិតខំបោសសម្អាតបទល្មើសនានា និង ការជម្រះមន្ទិលសង្ស័យ ចំពោះព័ត៌មានអវិជ្ជមាននានា ដែលទាក់ទងនឹងកិត្តិនាមរបស់កម្ពុជា គឺជាកត្តាចាំបាច់បំផុត ។
- ✓ ទី៣. បញ្ហាប្រឈម និង សំណូមពរ ដែលត្រូវការដំណោះស្រាយក្នុងរយៈពេលមធ្យម ៖ សំណូមពរមួយចំនួនពីវិស័យឯកជនទាមទារឱ្យមានការសិក្សា និង ពិគ្រោះយោបល់ឱ្យបានច្បាស់លាស់ មុននឹងដាក់ចេញជាវិធានការគោលនយោបាយដែលមានប្រសិទ្ធភាព។ ក្នុងន័យនេះ, សម្តេចធិបតីនាយករដ្ឋមន្ត្រី ស្នើឱ្យក្រសួងទេសចរណ៍សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ធ្វើការសិក្សាលទ្ធភាពអនុវត្តលើសំណើ ដែលមានដូចខាងក្រោម៖
  - ការបង្កើតខ្សែក្រវាត់បៃតងនៅតាមតំបន់ទេសចរណ៍សំខាន់ៗ ដើម្បីជំរុញការផ្គត់ផ្គង់បន្លែសាច់របស់ប្រជាកសិករដល់មូលដ្ឋានអាជីវកម្មទេសចរណ៍ និង

- ការអភិវឌ្ឍភ្នំគូលែនជាគោលដៅទេសចរណ៍ធម្មជាតិ ។

## ៧. ការអភិវឌ្ឍវិស័យកសិកម្ម និង កសិ-ឧស្សាហកម្ម៖

ក្នុងកិច្ចប្រជុំរវាងក្រុមការងារក្រសួងកសិកម្ម, រុក្ខាប្រមាញ់ និង នេសាទ និង វិស័យឯកជន, វិស័យឯកជនបានលើកឡើងនូវសំណើជាច្រើន, ទាំងផ្នែករដ្ឋបាល និង ផ្នែកពន្ធ, ដែលក្នុងនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានពិនិត្យ និង ដោះស្រាយនូវសំណើទាំងនេះ ស្ទើតែទាំងអស់រួចហើយ ។ បន្ថែមពីលើអ្វីដែលបានដោះស្រាយ រួចហើយនេះ, សម្តេចធិបតីនាយករដ្ឋមន្ត្រី សង្កត់ធ្ងន់លើវិធានការ ដូចខាងក្រោម៖

ទី១. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវអនុវត្តនូវកម្មវិធីអាទិភាពទាំង ៣ ដែល ខ្ញុំលើកឡើងខាងលើ ប្រកបដោយប្រសិទ្ធភាព និង ការទទួលខុសត្រូវខ្ពស់;

ទី២. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវជំរុញការផលិតគ្រាប់ពូជសុទ្ធ និង គុណភាពល្អ, ទាំងស្រូវ និង បន្លែ, ក៏ដូចជាជំរុញឱ្យមានការវិនិយោគពីវិស័យឯកជន ក្នុងការស្រាវជ្រាវ, អភិវឌ្ឍ និង ផលិតគ្រាប់ពូជ សម្រាប់ផ្គត់ផ្គង់ដល់កសិករ ឱ្យបាន ទូលំទូលាយ;

ទី៣. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវពន្លឿនការរៀបចំច្បាប់ស្តីពីផលិតកម្ម កសិកម្មតាមកិច្ចសន្យា ដើម្បីបង្កើនទំនុកចិត្តរវាងកសិករ និង ក្រុមហ៊ុនប្រមូលទិញ

ទី៤. ក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តវិធានការ ដែលបានទទួលការឯកភាពពីខ្ញុំ លើ លិខិតរបស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ១១០៣៣ សហវ.ល.ស.គសហ ស្តីពីរបាយការណ៍លទ្ធផលនៃកិច្ចប្រជុំពិភាក្សាពី ស្ថានភាពនៃការនាំចេញអង្ករ និង ស្វាយចន្ទីកម្ពុជា ។

## ៨. វិស័យធនាគារ និង ហិរញ្ញវត្ថុ៖

ភាពរីកចម្រើន និង ភាពរឹងមាំនៃវិស័យហិរញ្ញវត្ថុនៅកម្ពុជា បានរួមចំណែកយ៉ាងសំខាន់ ដល់ ការទ្រទ្រង់ និង ជំរុញកំណើនសេដ្ឋកិច្ចជាតិ ។ យ៉ាងណាមិញ, ការកើនឡើងនៃអត្រាការប្រាក់ ពីប្រភពទុនក្នុងស្រុក និង ក្រៅប្រទេស និង ការកើនឡើងនៃអតិផរណាជាសកល បាន និង កំពុងបង្កការប៉ះទង្គិចដល់គ្រឹះស្ថានធនាគារ និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ ទោះជាយ៉ាងនេះក្តី, រាជរដ្ឋាភិបាល និងធនាគារជាតិនៃកម្ពុជា មានការយល់ដឹងយ៉ាងច្បាស់អំពីភាពចាំបាច់ក្នុងការ ចាត់វិធានការរួមគ្នា សំដៅបន្តផ្តល់ភាពអនុគ្រោះ និង ជួយគាំទ្រដល់និរន្តរភាពនៃសកម្មភាព

អាជីវកម្មក្នុងវិស័យឯកជន ។ ក្នុងទិសដៅនេះ, ធនាគារជាតិនៃកម្ពុជានឹងបន្តបន្ធូរបន្ថយនូវបទប្បញ្ញត្តិប្រុងប្រយ័ត្នមួយចំនួន ដែលចាំបាច់ក្នុងការផ្តល់លទ្ធភាពឱ្យគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ បន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកគាំទ្រក្រុមហ៊ុន-សហគ្រាស ដូចជា ការផ្តល់ហិរញ្ញប្បទាន និងការរៀបចំឥណទានឡើងវិញ នៅក្នុងវិស័យដែលទទួលរងផលប៉ះពាល់ពីវិបត្តិ ។ វិធានការទាំងនោះ រួមមាន៖

- ទី១. អនុញ្ញាតឱ្យគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ បន្តអនុវត្តអនុបាតទ្រនាប់ដើមទុនខនស៊ើវេសិន ត្រឹមកម្រិត ១,២៥% រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤;
- ទី២. អនុញ្ញាតឱ្យគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ បន្តអនុវត្តអត្រាប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណត្រឹមកម្រិត ៧% រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤
- ទី៣. អនុញ្ញាតឱ្យគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ រៀបចំឥណទានឡើងវិញ ចំពោះវិស័យទេសចរណ៍នៅខេត្តសៀមរាប ជូនអតិថិជនដែលជួបប្រទះការលំបាកផ្នែកហិរញ្ញវត្ថុបណ្តោះអាសន្ន ដោយមិនចាំបាច់ធ្វើសំវិធានធន រយៈពេល ១២ ខែ; និង
- ទី៤. លើកទឹកចិត្តឱ្យគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ រៀបចំឥណទានឡើងវិញ ចំពោះវិស័យអចលនទ្រព្យ ជូនអតិថិជន ដែលជួបប្រទះការលំបាកផ្នែកហិរញ្ញវត្ថុបណ្តោះអាសន្ន ដោយត្រូវអនុវត្តម៉ឹងម៉ាត់តាមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា ។ គ្រឹះស្ថានត្រូវធ្វើការសិក្សា និង វិភាគច្បាស់លាស់អំពីស្ថានភាពរបស់អតិថិជន និង ផលប៉ះពាល់នៃឥណទានរបស់អតិថិជននោះ ចំពោះប្រព័ន្ធទាំងមូល ព្រមទាំងអាចស្នើសុំការពិភាក្សាជាមួយធនាគារជាតិនៃកម្ពុជា ដើម្បីពិចារណាអំពីវិធានការអនុគ្រោះតាមករណីជាក់ស្តែងបន្ថែមទៀត ។

## ៩. វិស័យរ៉ែ និង ថាមពល៖

### ៩.១. វិស័យរ៉ែ៖

ការធ្វើអាជីវកម្ម និង ការនាំចេញថ្មអារ៖ ជារួម, ដើម្បីឱ្យអាជីវកម្មថ្មអារអាចដំណើរការ និងមានលទ្ធភាពប្រកួតប្រជែងលើទីផ្សារអន្តរជាតិបាន, រាជរដ្ឋាភិបាល បានសម្រេចដាក់ចេញនូវវិធានការ ដូចខាងក្រោម ៖

- ✓ ទី១. គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តតាមខ្លឹមសារប្រកាសអន្តរក្រសួង លេខ ៦១៤ សហវ.ប្រក ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៧ ស្តីពីនីតិវិធី និង បែបបទ

សម្រាប់ការស្នើសុំនាំចេញផលិតផលរ៉ែ ដែលរាល់ការនាំចេញផលិតផលរ៉ែ ត្រូវតែមានវិញ្ញាបនបត្រ បញ្ជាក់ការនាំចេញ, ប៉ុន្តែ មិនអនុវត្តប្រការ ៨ នៃប្រកាសអន្តរក្រសួងនេះ ដែលតម្រូវឱ្យមន្ត្រីក្រសួងរ៉ែ និង ថាមពល ធ្វើការត្រួតពិនិត្យផលិតផលរ៉ែ មុនពេលនាំចេញម្តងៗនោះទេ ដោយទុកភារកិច្ចនេះជូនសមត្ថកិច្ចគយនៅតាមច្រកនាំចេញ ធ្វើការត្រួតពិនិត្យតែម្តង ។ មន្ត្រីគយត្រូវអនុវត្តការត្រួតពិនិត្យទំនិញនាំចេញ ក្នុងកម្រិតមិនលើសពី ៥% នៃបរិមាណទំនិញនាំចេញមួយលើកៗ ដោយពន្លឿនការត្រួតពិនិត្យនេះ ឱ្យបានឆាប់បំផុត តាមលទ្ធភាពដែលអាចធ្វើទៅបាន ។ ករណីរកឃើញបទល្មើស ឬ ភាពមិនប្រក្រតី, មន្ត្រីគយអាចពង្រីកវិសាលភាពនៃការត្រួតពិនិត្យ ដោយថាហេតុ ស្របតាមគោលការណ៍គ្រប់គ្រងហានិភ័យ និង តាមបទប្បញ្ញត្តិនានា ជាធរមាន ។ ចំពោះទំនិញនាំចេញ ៩៥% ដែលមិនជាប់កាតព្វកិច្ចត្រួតពិនិត្យ, ត្រូវពន្លឿន ដើម្បីឱ្យចេញបានឆាប់បំផុត ។ បន្ថែមលើនេះ, ត្រូវចាត់វិធានការមុតស្រួច ក្នុងការទប់ស្កាត់ការនាំចេញផលិតផលរ៉ែ ដោយខុសច្បាប់ ។

- ✓ ទី២. បន្តអនុវត្តតម្លៃមូលដ្ឋានគិតអាករនាំចេញតាមច្បាប់ស្តីពីគយ និង បទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ដែលស្របតាមគោលការណ៍នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ស្តីពីតម្លៃគិតពន្ធគយ គឺជាតម្លៃទិញលក់ពិត ។
- ✓ ទី៣. កែសម្រួលបញ្ចុះអត្រាអាករនាំចេញលើមុខទំនិញថ្ម ផ្អែកតាមរចនាសម្ព័ន្ធតារាងពន្ធគយ ជាធរមាន ដូចខាងក្រោម៖
  - បញ្ចុះអត្រាអាករនាំចេញពី ៣០% មក ១០% ចំពោះថ្មអារមិនទាន់កែច្នៃ ក្នុងជំពូក២៥ ដែលមានទម្រង់ជាដុំ (Block),
  - បញ្ចុះអត្រាអាករនាំចេញពី ៣០% មក ៥% ចំពោះថ្មអារមិនទាន់កែច្នៃ ក្នុងជំពូក ២៥ ដែលមានទម្រង់ជាបន្ទះ (Slab), និង
  - បញ្ចុះអត្រាអាករនាំចេញពី ២០% មក ០% ចំពោះថ្មកែច្នៃរួចគ្រប់ប្រភេទ ក្នុងជំពូក៦៨ ។
- ✓ ទី៤. ក្រសួងរ៉ែ និង ថាមពល និង អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា ត្រូវជំរុញការធ្វើសាមញ្ញកម្មនីតិវិធីនៃការចេញវិញ្ញាបនបត្របញ្ជាក់ការនាំចេញ, លិខិតអនុញ្ញាតគយនាំចេញ និង នីតិវិធីបំពេញបែបបទបញ្ចេញទំនិញពីគយ ឱ្យកាន់តែឆាប់រហ័ស និង មានប្រសិទ្ធភាព ដោយមិនត្រូវឱ្យលើស ៣ ថ្ងៃនៃថ្ងៃធ្វើការ រាប់ចាប់ពីថ្ងៃទទួលសំណុំឯកសារស្នើសុំត្រឹមត្រូវ និង គ្រប់គ្រាន់ ។

- ✓ ទី៥. ដាក់ចេញយន្តការអន្តរក្រសួង ដើម្បីសិក្សា និង ដាក់ឱ្យអនុវត្ត មូលនិធិស្តារការដ្ឋានរ៉ែ និង ស្តារបរិស្ថានឡើងវិញ, មូលនិធិថែទាំផ្លូវ និង អភិវឌ្ឍសហគមន៍ ដោយលើកអនុសាសន៍អនុវត្តការងារនេះ នៅរយៈពេល ៦ ខែក្រោយ ។ និង
- ✓ ទី៦. ក្រសួងរ៉ែ និង ថាមពល និង អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជាត្រូវបង្កើត Hot-line សម្រាប់ទទួល និង ដោះស្រាយសំណូមពររបស់ធុរជនវិស័យអាជីវកម្មថ្មអារ ។

## ៩.២ វិស័យថាមពល៖

កន្លងមក, រាជរដ្ឋាភិបាល ទទួលបានការស្នើសុំបញ្ចុះថ្លៃអគ្គិសនី និង ការអនុញ្ញាតឱ្យប្រើប្រាសថាមពលពន្លឺព្រះអាទិត្យលើដំបូល ។ ជុំវិញការបញ្ចុះថ្លៃអគ្គិសនី, ជាគោលការណ៍, រាជរដ្ឋាភិបាល តែងខិតខំបញ្ចុះថ្លៃអគ្គិសនី ឱ្យអស់លទ្ធភាព ដើម្បីកាត់បន្ថយថ្លៃដើមផលិតកម្ម ព្រមទាំងសម្រួលដល់ជីវភាពរស់នៅរបស់ប្រជាជន ។ ទោះជាយ៉ាងនេះក្តី, លទ្ធភាពនៃការបញ្ចុះថ្លៃអគ្គិសនី អាស្រ័យទៅតាមស្ថានភាពនិរន្តភាពនៃអាជីវកម្ម និង ស្ថិរភាពនៃការផ្គត់ផ្គង់ ដែលត្រូវមានការសិក្សាឱ្យបានច្បាស់លាស់ និង គ្រប់ជ្រុងជ្រោយ ។ ក្នុងស្ថានភាពដ៏លំបាក ដោយសារវិបត្តិជំងឺកូវីដ-១៩ និង នយោបាយសកលលោក ដែលបានធ្វើឱ្យកើតមានវិបត្តិថាមពល និង ការឡើងថ្លៃនៃប្រេងឥន្ធនៈ,ប្រទេសជាច្រើន, រួមទាំងប្រទេសជិតខាងរបស់កម្ពុជា, បានដំឡើងថ្លៃអគ្គិសនីជាបន្តបន្ទាប់ ដើម្បីទប់នឹងការខាតបង់អាជីវកម្ម ។ សម្រាប់កម្ពុជា, រាជរដ្ឋាភិបាល បាន និង កំពុង ខិតខំរក្សាថ្លៃអគ្គិសនីមិនឱ្យឡើង សំដៅជួយសម្រួលដល់អ្នកប្រើប្រាស់អគ្គិសនី និង អ្នកវិនិយោគទាំងអស់ ។ បន្ថែមលើនេះ, ដើម្បីរួមចំណែកជំរុញសេដ្ឋកិច្ចជាតិ, រាជរដ្ឋាភិបាលបានណែនាំឱ្យអគ្គិសនីកម្ពុជា ពិនិត្យលទ្ធភាពផ្តល់ថ្លៃអនុគ្រោះជូនអតិថិជនឧស្សាហកម្ម និង កសិកម្ម ចំពោះបរិមាណថាមពលប្រើលើសជាការលើក-ទឹកចិត្តដល់អ្នកវិនិយោគឱ្យបង្កើនការផលិត និង បង្កើនការងារបន្ថែម ។

# ១០. វិស័យសំណង់ និង អចលនទ្រព្យ៖

មុនការឆ្លងរាលដាលនៃជំងឺកូវីដ-១៩, វិស័យសំណង់ និង អចលនទ្រព្យ មានកំណើនខ្ពស់គួរឱ្យកត់សម្គាល់ និង បានក្លាយជាចន្ទល់កំណើនសេដ្ឋកិច្ចមួយដ៏សំខាន់សម្រាប់កម្ពុជា។ ក្រោយការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ រួមជាមួយនឹងវិបត្តិផ្សេងៗដែលធ្វើឱ្យប៉ះពាល់ដល់តម្រូវការ, ទាំងខាងក្នុង និងខាងក្រៅ, វិស័យនេះ ហាក់នៅទ្រឹង និង តម្រូវឱ្យមានការតាមដានជាប្រចាំ ។ រាជរដ្ឋាភិបាល នីតិកាលទី ៦ ក្រោមការដឹកនាំរបស់ **សម្តេចតេជោ ហ៊ុន សែន**, បាន

សិក្សាវាយតម្លៃស្ថានភាពនៃវិស័យនេះ និង បានដាក់ចេញនូវវិធានការជាកញ្ចប់ចំនួន **៨ ចំណុច** រួមបញ្ចូលទាំងផ្នែកសារពើពន្ធ និង ផ្នែករូបិយវត្ថុ ដើម្បីរក្សាលំនឹងវិស័យសំណង់ និង អចលនទ្រព្យ ដែលរួមមានដូចខាងក្រោម ៖

***ទី១.*** បន្តពន្យារពេលការអនុវត្តការបង់ពន្ធជាកញ្ចប់តាមដំណាក់កាល រហូតដល់ដំណាច់ឆ្នាំ ២០២៤ សម្រាប់ក្រុមហ៊ុនអភិវឌ្ឍន៍លំនៅឋានជាបុរី ដែលបាន និង កំពុងប្រតិបត្តិការគម្រោងអភិវឌ្ឍន៍លំនៅឋាន និង ដែលមានអាជ្ញាបណ្ណអាជីវកម្មអចលនវត្ថុ ផ្តល់ដោយនិយ័តករអាជីវកម្មអចលនវត្ថុ និង បញ្ចាំ ។ ដោយឡែក, ក្រុមហ៊ុនដែលបាន និង កំពុង ប្រតិបត្តិការគម្រោងអភិវឌ្ឍន៍លំនៅឋានជាបុរី ដែលគ្មានអាជ្ញាបណ្ណអាជីវកម្មអចលនវត្ថុ ត្រូវរួសរាន់ចុះបញ្ជីគម្រោងរបស់ខ្លួន ដើម្បីទទួលបានអាជ្ញាបណ្ណអាជីវកម្មអចលនវត្ថុ ស្របតាមនីតិវិធីជាធរមាន ពីនិយ័តករអាជីវកម្មអចលនវត្ថុ និង បញ្ចាំ យ៉ាងយូរត្រឹមដំណាច់ឆ្នាំ ២០២៣ ដើម្បីទទួលបានការបន្តការបង់ពន្ធជាកញ្ចប់ រហូតដល់ដំណាច់ឆ្នាំ ២០២៤ ។

ទី២. បង្កើនរយៈពេលនៃការបង់ពន្ធជាកញ្ចប់ តាមដំណាក់កាល ពី ១២ ខែ ដល់ ១៨ ខែ សម្រាប់ក្រុមហ៊ុនអ្នកអភិវឌ្ឍន៍លំនៅឋានជាបុរី ដែលបង់ពន្ធតិចជាង ១ លានដុល្លារអាម៉េរិក និង ពី ២៤ ខែ ដល់ ៣៦ ខែ សម្រាប់ក្រុមហ៊ុនអ្នកអភិវឌ្ឍន៍លំនៅឋានជាបុរី ដែលបង់ពន្ធលើសពី ១ លានដុល្លារអាម៉េរិក ។

ទី៣. ក្រុមហ៊ុនអ្នកអភិវឌ្ឍន៍លំនៅឋានជាបុរីថ្មី ឬ ក្រុមហ៊ុនដែលមានគម្រោងអភិវឌ្ឍន៍លំនៅឋានជាបុរីដែលមិនទាន់អភិវឌ្ឍ ត្រូវបង់ពន្ធស្របតាមនីតិវិធីជាធរមាន (របបពិត) និង ត្រូវកាន់បញ្ជីគណនេយ្យឱ្យបានត្រឹមត្រូវ ។

ទី៤. បន្តពន្យារពេលការអនុវត្តពន្ធលើចំណេញមូលធន សម្រាប់តែវិស័យអចលនទ្រព្យ រហូតដល់ដំណាច់ឆ្នាំ ២០២៤ ។

ទី៥. បន្តការលើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់លំនៅឋានគ្រប់ប្រភេទ ដែលមានលក្ខណៈជាបុរី និង ដែលមានថ្លៃក្រោម ឬ ស្មើ ៧ ម៉ឺនដុល្លារអាម៉េរិក រហូតដល់ដំណាច់ឆ្នាំ ២០២៤ ។

ទី៦. លើកទឹកចិត្ត និង ស្នើឱ្យគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ធ្វើការរៀបចំឥណទានឡើងវិញ តាមលទ្ធភាពជាក់ស្តែងរបស់គ្រឹះស្ថាន ដោយផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត និង ការព្រមព្រៀងរវាងគ្រឹះស្ថាន និង ក្រុមហ៊ុនអភិវឌ្ឍន៍លំនៅឋានជាបុរី ដោយអនុលោមតាមប្រកាស លេខ ធ៧.០១៧.៣៤៤ ប្រក ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៧ ស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និង សំវិធានធនលើអីមភែរមិន ។

ទី៧. លើកលែងការផាកពិន័យផ្សេងៗ ចំពោះគម្រោងអភិវឌ្ឍន៍លំនៅឋានជាបុរី, ប៉ុន្តែក្រុមហ៊ុនអភិវឌ្ឍន៍ចាំបាច់ត្រូវបំពេញកាតព្វកិច្ច ស្របតាមប្រកាសលេខ ០៨៩ សហវ.ប្រក ស្តីពី «ការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ» ។ និង

ទី៨. ពន្យារពេលអនុវត្តរហូតដល់ដំណាច់ឆ្នាំ ២០២៣ លើសេចក្តីប្រកាសលេខ ៥៦៣ សហវ.ប្រក ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០២០ ស្តីពី «កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ» ចេញដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

រាជរដ្ឋាភិបាល នាពេលនោះ ក៏បានបង្កើតនូវក្រុមការងារអន្តរក្រសួង ចំនួន ២ ដើម្បីតាមដាន និងដោះស្រាយបញ្ហាប្រឈមនៅក្នុងវិស័យនេះ រួមមាន៖ (១). ក្រុមការងារអន្តរក្រសួង-ស្ថាប័ន ដើម្បីដោះស្រាយបញ្ហាវិវាទផ្សេងៗ ក្នុងវិស័យអចលនទ្រព្យ, និង (២). ក្រុមការងារអន្តរក្រសួង-ស្ថាប័ន កម្រិតគោលនយោបាយ និង ម៉ាក្រូសេដ្ឋកិច្ច សម្រាប់វាយតម្លៃស្ថានភាពវិស័យសំណង់ និង អចលនទ្រព្យ ដើម្បីបន្តដោះស្រាយបញ្ហាបន្ទាន់ និង សិក្សា, វិភាគ និង ដាក់ចេញនូវគោលនយោបាយ សំដៅជានាការអភិវឌ្ឍប្រកបដោយចីរភាព នៃវិស័យសំណង់ និង អចលនទ្រព្យ ។ ដើម្បីបង្កើនការជួយដល់វិស័យសំណង់ និង អចលនទ្រព្យ, សម្តេចធិបតី នាយករដ្ឋមន្ត្រី បានដាក់ចេញនូវវិធានការបន្ថែម ដូចខាងក្រោម៖

- ✓ ទី១. លើកលែងពន្ធប្រថាប់ត្រាបន្ថែមទៀតលើការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់លំនៅឋានគ្រប់ប្រភេទ ដែលមានលក្ខណៈជាបុរី និង មានថ្លៃលើស ៧ ម៉ឺនដុល្លារអាម៉េរិក ដោយអនុញ្ញាតឱ្យដកទំហំទឹកប្រាក់ ៧ ម៉ឺនដុល្លារអាម៉េរិក ចេញពីមូលដ្ឋានគិតពន្ធប្រថាប់ត្រា សម្រាប់ការទិញលំនៅឋានក្នុងគម្រោងអភិវឌ្ឍន៍លំនៅឋានជាបុរី ដែលមានអាជ្ញាបណ្ណអាជីវកម្មអចលនវត្ថុ និង បានចុះបញ្ជីត្រឹមត្រូវ រហូតដល់ដំណាច់ឆ្នាំ ២០២៤ ។ តាមរយៈវិធានការនេះ, អ្នកទិញលំនៅឋានគ្រប់ប្រភេទ នឹងទទួលបាននូវការលើកទឹកចិត្ត ពោលគឺ សម្រាប់អ្នកមានធនធានតិចដែលទិញផ្ទះក្នុងថ្លៃចាប់ពី ៧ ម៉ឺនដុល្លារអាម៉េរិកចុះ នឹងត្រូវបានរួចពន្ធប្រថាប់ត្រា ហើយសម្រាប់អ្នកដែលទិញលំនៅឋានមានថ្លៃលើស ៧ ម៉ឺនដុល្លារអាម៉េរិក ក៏នឹងទទួលបាននូវការលើកទឹកចិត្ត តាមរយៈការដកទឹកប្រាក់ ៧ ម៉ឺនដុល្លារអាម៉េរិក ចេញពីមូលដ្ឋានគិតពន្ធផងដែរ, ឧទាហរណ៍៖ ប្រសិនបើលំនៅឋានដែលជាកម្មវត្ថុនៃការទិញ មានថ្លៃ ១០ ម៉ឺនដុល្លារអាម៉េរិក, នោះមូលដ្ឋានសម្រាប់គិតពន្ធប្រថាប់ត្រា នឹងនៅសល់ត្រឹមតែ ៣ ម៉ឺនដុល្លារអាម៉េរិកប៉ុណ្ណោះ (ពោលគឺ ១០ ម៉ឺនដុល្លារ - ៧ ម៉ឺនដុល្លារ = ៣ ម៉ឺនដុល្លារ) ។ និង

✓ ទី២. ការផ្តល់សិទ្ធិដល់ជនបរទេសទិញលំនៅឋាន៖ ទាក់ទិននឹងការស្នើសុំរបស់វិស័យឯកជនឱ្យរាជរដ្ឋាភិបាលផ្តល់ការអនុញ្ញាតឱ្យជនបរទេស មានសិទ្ធិទិញលំនៅឋាន (ដី និង ផ្ទះ) សម្រាប់ការប្រើប្រាស់ និង មានសិទ្ធិជាម្ចាស់កម្មសិទ្ធិស្របច្បាប់, សម្តេចធិបតីនាយករដ្ឋមន្ត្រី សូមយកវេទិកានេះបញ្ជាក់ឱ្យបានច្បាស់ថា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និង បទដ្ឋានគតិយុត្តពាក់ព័ន្ធ មិនបានអនុញ្ញាតឱ្យជនបរទេស, ទាំងជារូបវន្តបុគ្គល, ទាំងជានីតិបុគ្គល, អាចក្លាយជាម្ចាស់កម្មសិទ្ធិលើដីធ្លីនោះឡើយ ពោលគឺ មានតែរូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី ។ យ៉ាងណាមិញ, បន្ទាប់ពីធ្វើការសិក្សា និង ពិនិត្យឡើងវិញនូវបទដ្ឋានគតិយុត្តដែលមានស្រាប់, កម្ពុជាក៏មានយន្តការដែលផ្តល់សិទ្ធិឱ្យជនបរទេសអាចទិញ និង កាន់កាប់អចលនទ្រព្យ ដោយមានសិទ្ធិស្ទើរតែដូចគ្នានឹងសិទ្ធិរបស់កម្មសិទ្ធិករដែរ តាមរយៈយន្តការចំនួន ៣ ដូចខាងក្រោម៖

- **យន្តការតាមរយៈតំណាងជាជនជាតិខ្មែរ៖** យន្តការនេះ អនុញ្ញាតិឱ្យជនបរទេសអាចទិញដីបានតាមរយៈតំណាងជនជាតិខ្មែរ, ប៉ុន្តែ នៅលើប័ណ្ណកម្មសិទ្ធិត្រូវដាក់ឈ្មោះអ្នកតំណាងជាជនជាតិខ្មែរ ហើយដើម្បីការពារដល់អ្នកវិនិយោគបរទេសទាំងនោះ ពួកគេត្រូវតែមានកិច្ចសន្យាជានាជាមួយអ្នកតំណាងរបស់ខ្លួន ។
- យន្ត**ការតាមរយៈក្រុមហ៊ុនបរធនបាល (Trust Company)៖** យោងតាមច្បាប់ស្តីពី បរធនបាលកិច្ច ឆ្នាំ ២០១៩, ជនបរទេសអាចទិញដីនៅកម្ពុជាបាន តាមរយៈក្រុម-ហ៊ុនបរធនបាល ដែលបានចុះបញ្ជីបរធនបាលកិច្ចនៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រឹមត្រូវ ពោលគឺជនបរទេសអាចទិញទ្រព្យសម្បត្តិ ដោយមានក្រុមហ៊ុនបរធនបាលដើរតួជាអ្នកគ្រប់គ្រងទ្រព្យសម្បត្តិនេះ តែក្រុមហ៊ុននោះគ្មានសិទ្ធិយកទៅលក់បន្តឡើយ ដរាបណាមិនមានការយល់ព្រមពីជនបរទេសដែលជាម្ចាស់ទ្រព្យ ។ និង
- យន្ត**ការវិនិយោគតំបន់ទេសចរណ៍ពិសិដ្ឋ** ដែលក្នុងនោះ ម្ចាស់តំបន់, ដៃគូតំបន់ ឬ ទេសចរពិសេស អាចទទួលបានការលើកទឹកចិត្ត ដូចជា៖ (១). អាចទទួលបានទិដ្ឋាការចេញចូលកម្ពុជាច្រើនដង ឬ ការលើកលែងទិដ្ឋាការ និង ស្នាក់នៅរយៈពេលយូរ ស្របតាមច្បាប់កំណត់ ឬ អាចប្រើប្រាស់ប័ណ្ណអនុញ្ញាតចេញចូលពិសេស ពី រាជរដ្ឋាភិបាល, និង (២). អាចទទួលបានសិទ្ធិកម្មសិទ្ធិ ឬ សិទ្ធិប្រើប្រាស់អាស្រ័យ-ផល លើអចលនទ្រព្យនៅក្នុងតំបន់ទេសចរណ៍ពិសិដ្ឋ ។

មុននឹងបិទបញ្ចប់វេទិការបស់យើង, សម្តេចធិបតីនាយករដ្ឋមន្ត្រី បានដាក់ចេញនូវការងារបន្តមួយចំនួន ដែលក្រសួង-ស្ថាប័ន ត្រូវយកចិត្តទុកដាក់អនុវត្ត ដូចខាងក្រោម៖

ទី១. ក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវខិតខំជំរុញការអនុវត្តវិធានការ ដែលបានដាក់ចេញខាងលើ ក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ដោយមានការរៀបចំសូចនាករគន្លឹះ និង ក្របខណ្ឌពេលច្បាស់លាស់ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត ។

ទី២. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវតាមដាន និងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តវិធានការខាងលើ និង រាយការណ៍មករាជរដ្ឋាភិបាលជាប់ជាប្រចាំ រៀងរាល់ ៦ ខែម្តង ។

ទី៣. វិធានការដែលបានដាក់ចេញខាងលើ អាចមានចរិតជារចនាសម្ព័ន្ធ, ប្រព័ន្ធ ឬ អន្តរវិស័យ ព្រមទាំងមានលក្ខណៈបន្ទាន់។ ជាការពិត, បញ្ហាប្រឈមមួយចំនួនទៀត ដែលបានលើកដោយវិស័យឯកជនមិនទាន់ត្រូវបានដោះស្រាយនាពេលនេះ តែនឹងត្រូវបានដោះស្រាយក្នុងរយៈពេលមធ្យម។ ក្នុងន័យនេះ, សម្តេចធិបតីនាយករដ្ឋមន្ត្រី ប្រគល់ភារកិច្ចជូនគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការរៀបចំ «កម្មវិធីលើកកម្ពស់ភាពប្រកួតប្រជែង, បង្កើនពិពិធកម្ម និង ពង្រឹងភាពធន់ ដើម្បីកំណើនសេដ្ឋកិច្ច នៅក្នុងបរិការណ៍សកល ដែលមានភាពមិនប្រាកដប្រជាខ្ពស់» សម្រាប់រយៈពេល ៤ ឆ្នាំ ពីឆ្នាំ ២០២៤ ដល់ឆ្នាំ ២០២៨ ដែលត្រូវរួមបញ្ចូលផងដែរ នូវការគិតគូរដោះស្រាយបញ្ហាធំៗមួយចំនួន ដែលវិស័យឯកជន បានលើកឡើង មានជាអាទិ៍៖

- ✓ ការអភិវឌ្ឍធនធានមនុស្ស និង បណ្តុះបណ្តាលវិជ្ជាជីវៈ;
- ✓ ការជំរុញការអភិវឌ្ឍសហគ្រាសធុនមីក្រូ, តូច និង មធ្យម;
- ✓ ការបង្កើនភាពទាក់ទាញសម្រាប់ការវិនិយោគផ្ទាល់ពីបរទេស;
- ✓ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែង;
- ✓ ការអនុវត្តផែនការមេអភិវឌ្ឍខេត្តព្រះសីហនុ ឱ្យទៅជាតំបន់សេដ្ឋកិច្ចពិសេសគម្រូពហុបំណង;
- ✓ ការជំរុញការអភិវឌ្ឍវិស័យកសិកម្ម និងវិស័យទេសចរណ៍;
- ✓ ការជំរុញការអភិវឌ្ឍឧស្សាហកម្មថ្មីៗ ដូចជា វិស័យយានយន្ត និង អេឡិចត្រូនិកកម្ពុជា ជាដើម;
- ✓ កិច្ចសម្រួលពាណិជ្ជកម្ម ជាពិសេសការជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីកាត់បន្ថយឱ្យអស់នូវការប្រើប្រាស់ឯកសារនាំចេញ-នាំចូល ក្នុងទម្រង់រឹង ឱ្យបានក្នុងរយៈពេល ៤ ឆ្នាំ;

- ✓ ការអភិវឌ្ឍការដឹកជញ្ជូនតាមផ្លូវដែកដែលមានបច្ចុប្បន្ន ឱ្យមានប្រសិទ្ធភាព និង ថ្លៃសមរម្យ; និង
- ✓ ការជំរុញការកែសម្រួលឱ្យកាន់តែមានភាពប្រកួតប្រជែងបន្ថែមទៀត នូវ បរិយាកាសធុរកិច្ច និង ការវិនិយោគ ជាដើម ។

ទី៤. សម្តេចធិបតីនាយករដ្ឋមន្ត្រី ផ្តល់ការឯកភាពជាគោលការណ៍ដល់ការបង្កើតក្រុមការងារតាមវិស័យចំនួន ១ បន្ថែមទៀត តាមការស្នើសុំរបស់វិស័យឯកជន គឺ ក្រុមការងារសេដ្ឋកិច្ច និង សង្គមឌីជីថល និង ទូរគមនាគមន៍ (ក្រុម "ណ") ។ ដូច្នេះ, ក្រុមការងារតាមវិស័យនៅក្រោមយន្តការវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន នឹងមានចំនួនសរុប ចំនួន ១៥ ។

ទី៥. សម្តេចធិបតីនាយករដ្ឋមន្ត្រី ណែនាំឱ្យក្រុមការងារតាមវិស័យទាំង ១៥ ត្រូវសហការជិតស្និទ្ធជាមួយផ្នែកឯកជន ដោយរៀបចំកិច្ចប្រជុំឱ្យបានទៀងទាត់ និង ខិតខំដោះស្រាយឱ្យអស់នូវរាល់បញ្ហាប្រចាំថ្ងៃ របស់វិស័យឯកជន ដោយមិនត្រូវរង់ចាំការរៀបចំវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនឡើយ ។ ទន្ទឹមនេះដែរ, ដោយក្រុមការងារសេដ្ឋកិច្ច និង សង្គមឌីជីថល និង ទូរគមនាគមន៍ទើបតែត្រូវបានបង្កើត, ខ្ញុំសូមស្នើឱ្យមានការរៀបចំសមាសភាពឱ្យបានឆាប់ ហើយចាប់ផ្តើមប្រជុំ ដើម្បីស្តាប់ និង ដោះស្រាយនូវបញ្ហាប្រឈម ជូនវិស័យឯកជន ។